កាតព្វកិច្ចរបស់ឪពុកម្តាយ

The Duties of Parents

J.C.Ryle

រក្សាសិទ្ធិគ្រប់បែបយ៉ាង ដោយអ្នកនិពន្ធដើម @ ២០២៤
និពន្ធដោយ៖ លោកគ្រូ J. C. Ryle
បកប្រែដោយមានការអនុញ្ញាតពី Desiring God Foundation
All rights reserved by original authors © 2024
Used by permission
ផលិតដោយ៖ អង្គការសកម្មភាពកម្ពុជា resources@actioncambodia.org

បកប្រែដោយ៖ លោក វេន ប៉ុក
ជំនួយការបកប្រែដោយ៖ លោក ឈាង ប៉ូវ៉ា
ពិនិត្យផ្ទៀងផ្ទាត់ដោយ៖ លោក វែល ណាថាន, លោក ទេព រ៉ូ, អ្នកស្រី ឡូញ ស្រីរដ្ឋ, លោក ខែម បូឡុង, លោក ហុង សម្ភស, លោក ឡង់ គីមឡុង, លោក ឯក សត្យា, លោក ស៊ូ ទិត្យ លោក ជឿន ជីវិចន្ធា, លោកស្រី ថាវ ប៊ុនរី, លោកស្រី ហង្ស សោភ័ណ, លោក ង៉ែត វិទូ,
លោក លឹម ម៉ៅ, និងលោក ជេហ្វ ឡៃ

ការប្រើប្រាស់បទព្រះគម្ពីរបរិសុទ្ធ និងជីវិសុទ្ធ និងព្រះគម្ពីរសញ្ញាថ្មីកែសម្រួលឆ្នាំ២០១៤មានការអនុញ្ញាតពីសមាគមព្រះគម្ពីរកម្ពុជា និងរក្សាសិទ្ធិដោយសមាគមព្រះគម្ពីរសកល-ដកស្រង់ដោយមានការអនុញ្ញាត។
មានការអនុញ្ញាតការប្រើប្រាស់បទព្រះគម្ពីរគ្រិស្តបរិស័ទខ្មែរ-សញ្ញាថ្មី រក្សាសិទ្ធិ © ២០១២ ព័ន្ធកិច្ចព្រះបន្ទូលនៃជីវិត។ យើងខ្ញុំបានរក្សាអក្ខរាវិរុទ្ធនៃសម្រង់ខគម្ពីរដែលមាននៅក្នុងព្រះគម្ពីរបកប្រែចាស់ឆ្នាំ១៩៥៤, ព្រះគម្ពីរបរិសុទ្ធកែសម្រួលឆ្នាំ២០១៦ (គកស), ព្រះគម្ពីរជីវិសុទ្ធជាភាសាខ្មែរបច្ចុប្បន្ន (គខប), ព្រះគម្ពីរគ្រិស្តបរិស័ទខ្មែរ (គគខ), ក៏ដូចជាអសាធារណនាមមួយចំនួន ប៉ុន្តែសំណេរនៅក្នុងអត្ថបទទាំងមូលយើងខ្ញុំបានខិតខំព្យាយាមគោរពតាមអក្ខរាវិរុទ្ធនៃវចនានុក្រមខ្មែររបស់សម្តេចសង្ឃរាជ ជួន ណាត។
អ្នករចនាអត្ថបទភាសាខ្មែរ៖ លោក វែល ណាថាន និងលោក ស៊ូ ទិត្យ
For ordering information please visit:
ប្រសិនបើលោកអ្នកចង់ជាវសៀវភៅនេះ សូមចូលទៅកាន់គេហទំព័រ៖ plovpitshop.com
បោះពុម្ពលើកទី១ ចំនួន៣០០០ក្បាល គ.ស. ២០២៤ នៅព្រះរាជាណាចក្រកម្ពុជា

មាតិកា

អារម្ភកថា.....

៣

សេចក្តីផ្តើម.....

៩

ជំពូក១

បណ្តុះបណ្តាលគេនៅក្នុងរបៀបដែលគេត្រូវទទួល មិនមែនតាមរបៀបដែល
ពួកគេប្រាថ្នាចង់បានទេ.....

១៣

ជំពូក២

សូមបណ្តុះបណ្តាលកូនរបស់លោកអ្នក
ដោយភាពទន់ភ្លន់ ក្តីស្រឡាញ់ និងភាពអត់ធ្មត់.....

១៥

ជំពូក៣

សូមបណ្តុះបណ្តាលកូនរបស់លោកអ្នកជាមួយជំនឿយ៉ាងខ្ជាប់ខ្ជួន ដោយ
ការពឹងផ្អែកភាគច្រើននៅលើលោកអ្នក.....

២១

ជំពូក៤

សូមបណ្តុះបណ្តាលជាមួយនឹងគំនិតនេះបន្តជានិច្ចនៅចំពោះមុខលោកអ្នកថា
ព្រលឹងរបស់កូនលោកអ្នក គឺជារឿងដំបូងដែលត្រូវគិតពិចារណា.....

២៥

ជំពូក៥

សូមបណ្តុះបណ្តាលកូនរបស់លោកអ្នក
អំពីចំណេះដឹងនៃព្រះគម្ពីរ.....
២៩
ជំពូក៦
សូមបណ្តុះបណ្តាលគេឲ្យមានទម្លាប់នៃការអធិស្ឋាន.....
៣៣

ជំពូក៧
សូមបង្ហាត់បង្រៀនពួកគេឲ្យមានទម្លាប់ឧស្សាហ៍ព្យាយាម ហើយមានភាព
ទៀងទាត់ក្នុងការចូលរួមនៅក្នុងក្រុមជំនុំ.....
៣៩
ជំពូក៨
សូមបណ្តុះបណ្តាលពួកគេជាមួយទម្លាប់នៃជំនឿ.....
៤៥
ជំពូក៩
បណ្តុះបណ្តាលកូនរបស់លោកអ្នកឲ្យមានទម្លាប់
នៃការស្តាប់បង្គាប់ .....
៤៩
ជំពូក១០
សូមបណ្តុះបណ្តាលពួកគេជាមួយទម្លាប់
នៃការនិយាយការពិត .....
៥៣
ជំពូក១១
សូមបណ្តុះបណ្តាលពួកគេឲ្យមានទម្លាប់

នៃការតែងតែមិនខ្ជះខ្ជាយពេលវេលា.....
៥៧
ជំពូក១២
សូមបណ្តុះបណ្តាលពួកគេជាមួយការភ័យខ្លាច
នៃការបណ្តោយខ្លួនហួសហេតុដោយឥតឈប់ឈរ.....
៦១
ជំពូក១៣
សូមបណ្តុះបណ្តាលពួកគេដោយចងចាំអំពីរបៀប
ដែលព្រះបណ្តុះបណ្តាលកូនៗរបស់ទ្រង់ជានិច្ច.....
៦៩
ជំពូក១៤
សូមបណ្តុះបណ្តាលពួកគេដោយនឹកចាំអំពីឥទ្ធិពល
នៃគំរូរបស់លោកអ្នកផ្ទាល់ជានិច្ច.....
៧៥
ជំពូក១៥
សូមបណ្តុះបណ្តាលពួកគេដោយចងចាំជានិច្ចនូវអំណាចនៃអំពើបាប.....
៧៩
ជំពូក១៦
សូមបណ្តុះបណ្តាលពួកគេដោយបន្តចងចាំជានិច្ច
នូវព្រះបន្ទូលសន្យា.....
៨៣
ជំពូក១៧
ចុងក្រោយ សូមបង្ហាត់ពួកគេដោយការអធិស្ឋាន

អារម្ភកថា

«កាតព្វកិច្ចរបស់ឪពុកម្តាយ» ឬតួនាទីរបស់ឪពុកម្តាយគឺពិតជាមិនមែនរឿងងាយស្រួលឡើយ ហើយខ្ញុំជឿថា ឪពុកម្តាយគ្រប់រូបសុទ្ធតែចង់ធ្វើជាឪពុកម្តាយល្អ ចិញ្ចឹមបីបាច់កូនឲ្យបានធំធាត់ និងលូតលាស់មានអនាគតល្អប្រសើរ ក្លាយជាមនុស្សល្អ ជាធនធានមនុស្សល្អ មានសេចក្តីស្រលាញ់ ចិត្តល្អ គោរពកោតខ្លាចព្រះជាម្ចាស់ ចេះជួយយកអាសាអ្នកដទៃ។ល។ ប៉ុន្តែ កិច្ចការទាំងអស់នេះមិនអាចកើតឡើងដោយឯកឯងបានទេ គឺវាទាមទារការខិតខំប្រឹងប្រែង ការលះបង់ ការចុះចូលរបស់ឪពុកម្តាយ។ ហើយកាន់តែពិបាកជាងនេះទៅទៀតគឺនៅក្នុងយុគសម័យទំនើបនេះ ដែលកូនៗរបស់យើងរស់នៅជាមួយបច្ចេកវិជ្ជា ដែលគេតែងនិយាយថា (អ្វីៗនៅក្នុងកណ្តាប់ដៃរបស់យើង) នោះគឺស្មាតហ្វូន (smart phone) ដែលដៃរបស់យើងអាចបញ្ជាចេញ និងស្វែងរក។ វាមានការជះឥទ្ធិពលល្អ និងអាក្រក់។ ហើយឪពុកម្តាយក៏មមាញឹកនៅក្នុងការប្រកបអាជីវកម្ម ធ្វើការងារដែលមិនមានពេលគ្រប់គ្រាន់ចំណាយពេលជាមួយកូន បង្ហាត់បង្រៀនកូនៗបានច្រើនដែរ។ កូនៗយើងបានចំណាយពេលវេលាសឹងតែពេញមួយថ្ងៃនៅសាលារៀន ពេលមកដល់ផ្ទះគេធ្វើកិច្ចការសាលា ហើយញ៉ាំបាយជុំគ្នា គ្រួសារខ្លះមិនបានញ៉ាំបាយជុំគ្នាផង ហើយចូលគេង ក្រោកឡើងបន្តទម្លាប់ដដែលបែបនោះទៀត។

ដូច្នេះ សំណួរសួរថា *តើយើងនឹងបង្ហាត់បង្រៀនកូនៗរបស់យើងបានយ៉ាងដូចម្តេច?* ទោះជាយ៉ាងណាយើងអាចរកឃើញគន្លឹះមួយចំនួនដែលអ្នកនិពន្ធសៀវភៅ «កាតព្វកិច្ចរបស់ឪពុកម្តាយ» នេះបានលើកឡើង ពិតជាមានសារៈសំខាន់សម្រាប់ឪពុកម្តាយគ្រប់រូបគួរគិតពិចារណា។

ទីមួយ៖ ពេលនៅផ្ទះ

គាត់បាននិយាយថា ផ្ទះគឺជាកន្លែងដែលបណ្តុះបណ្តាល២៤ម៉ោង/១ថ្ងៃ ៧ថ្ងៃ/១សប្តាហ៍ ដែលកូនៗរបស់លោកអ្នកអាចរៀនបានពីផ្ទះនៅផ្ទះ។ ផ្ទះគឺជាកន្លែងដែលបង្កើតទម្លាប់ គឺជាកន្លែងដែលចាក់គ្រឹះនៃចរិតលក្ខណៈ ផ្ទះដល់នូវទំនោរ ចំណង់ចំណូលចិត្ត ដួងចិត្ត និងគំនិតរបស់ពួកគេផងដែរ។ ខ្ញុំចូលចិត្តពាក្យចាក់គ្រឹះយើងត្រូវប្រាកដថាកូនៗរបស់យើងគួរតែចាក់គ្រឹះមាំនៅក្នុងផ្ទះរបស់ពួកគេ និងនៅក្នុងចិត្ត ជីវិតរបស់ពួកគេ។ សម្រាប់ខ្ញុំគ្រឹះមាំនៅក្នុងជីវិតកូនៗរបស់ខ្ញុំគឺអង្គព្រះយេស៊ូវ។ ខ្ញុំបង្រៀនពួកគេឲ្យយកព្រះយេស៊ូវ ជាគ្រប់ទាំងអស់ ហើយគ្រប់ទាំងអស់មាននៅក្នុងព្រះយេស៊ូវ។ ខ្ញុំលើកទឹកចិត្តពួកគេឲ្យអានព្រះគម្ពីរ តិចក្តី ឬច្រើនក្តី និងអធិស្ឋានមុនគេបង្អស់ពេលមានរឿងអ្វីកើតឡើង។

សៀវភៅនេះបានណែនាំឲ្យឪពុកឲ្យម្តាយយកចិត្តទុកដាក់ទៅលើព្រលឹងកូនៗរបស់ខ្លួន ដែលខ្ញុំគិតថារាជាចំណុចសំខាន់ ហើយណែនាំកូនៗឲ្យពួកគេមានជំនឿ ឲ្យចេះអធិស្ឋាន បណ្តុះទម្លាប់ឲ្យពួកគេនិយាយការពិត ស្តាប់បង្គាប់ ប្រើប្រាស់ពេលវេលាឲ្យបានត្រឹមត្រូវ។

ការយកឈ្នះ និងរបៀបចូលទៅកាន់កូនៗ និងការបង្កើតទម្លាប់ទៅក្រុមជំនុំ ជាមួយកូនៗជាប្រចាំ។

ទីពីរ៖ ក្រុមជំនុំ

សម្រាប់ខ្ញុំការទៅក្រុមជំនុំជាមួយកូនៗរាល់សប្តាហ៍ពិតជាលើកទឹកចិត្តខ្ញុំ ពីព្រោះពេលខ្លះខ្ញុំអស់កម្លាំង ហត់នឿយ តែខ្ញុំគិតថាបើខ្ញុំអត់ទៅ នោះកូនខ្ញុំក៏អត់ទៅដែរ។ ហើយក្រោយមករាល់សប្តាហ៍កូនខ្ញុំជាអ្នករម្លឹក ខ្ញុំក្នុងការទៅក្រុមជំនុំ នេះជាសម្តីកូនកូនពៅរបស់ខ្ញុំពេលថ្ងៃសៅរ៍ «ម៉ាក់ស្អែកយើងទៅ Church អត់?» ហើយការអង្គុយជាមួយគ្នាក្នុងក្រុមជំនុំ ពេលខ្លះខ្ញុំគិតថាកូនរបស់ខ្ញុំស្រីៗ ប្រហែលជាស្តាប់មិនយល់ទេមើលទៅ តែពួកគេយល់ហើយកត់សេចក្តីបង្រៀនបានថែមទៀតផង (កូនស្រីទីពីរខ្ញុំចូលចិត្តកត់មេរៀនគ្រូ) ហើយក៏មានពេលខ្លះ (កូនស្រីទីមួយរបស់យើងងោកងុយពេលគ្រូអធិប្បាយក៏មានដែរ) តែពួកគេមិនដែលអាក់ខានទេ លើកលែងតែករណីចាំបាច់បំផុត។

នៅក្នុងជំពូក១២ អ្នកនិពន្ធបានលើកឡើងអំពីការដាក់វិន័យដល់កូនៗ គាត់លើកទឹកចិត្តកុំបណ្តោយឲ្យកូនធ្វើអ្វីតាមចិត្តរបស់ពួកគេឡើយ។ ត្រូវនិយាយថា *«ទេ»* ជាមួយកូនៗរបស់យើងនូវអ្វីដែលមិនសមហេតុសមផល និងអ្វីដែលអាចបង្កការគ្រោះថ្នាក់ដល់ពួកគេផងដែរ។ ក្មេងៗធំធាត់ឡើងមានទំនោរទៅរកការប្រព្រឹត្តអំពើបាប ពួកគេចង់ធ្វើដូចជាមិត្តភក្តិរបស់គេ ពួកគេចង់សាកល្បងអ្វីដែលថ្មី ការបង្រៀនខ្លះពួកគេទទួលបានតាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គម...។

ហេតុដូច្នេះ យើងត្រូវពន្យល់ណែនាំពួកគេដោយសេចក្តីស្រឡាញ់ស្លូតបូត ដោយឲ្យពួកគេដឹងថាការបដិសេធរបស់យើងគឺសម្រាប់ការល្អដល់ពួកគេ និងដោយសារតែយើងស្រឡាញ់ពួកគេ។ ខ្ញុំបានប្រើពាក្យនេះជាមួយកូនស្រីជំទង់របស់ខ្ញុំ កាលពីគេអាយុ១៣ឆ្នាំ *«គេធ្វើបានតែយើងធ្វើអត់បានទេកូន»*។ ដោយសារតែគាត់បានសួរថា *«ហេតុអ្វីបានជាមិត្តភក្តិរបស់គាត់ធ្វើការនេះការនោះបាន»* តែគាត់ធ្វើមិនបាន។ ខ្ញុំបានពន្យល់ដល់គាត់ថា *«យើងជាគ្រីស្ទបរិស័ទដូច្នេះមានការខ្លះដែលយើងធ្វើអត់បានទេ»*។ ហើយមានចំណុចខ្លះយើងបានប្រាប់គាត់ថា *«គាត់មិនទាន់ស្គាល់អំពីសង្គមខាងក្រៅនិងមិនដឹងថាមានរឿងអ្វីខ្លះអាចកើតឡើងជាហេតុ»*។ គាត់ថែមទាំងសួរទៀតថា *«បើអញ្ចឹង ម៉ាក់មិនទុកចិត្តកូនទេឬ?»*។ យើងឆ្លើយថា *«ម៉ាក់ទុកចិត្តកូន តែម៉ាក់មិនទុកមនុស្សដែលនៅជុំវិញកូន ម៉ាក់មិនស្គាល់ពួកគេ ម៉ាក់មិនទុកចិត្តកន្លែងដែលកូនទៅទេ...»*។ល។ ដំបូងកូនស្រីគាត់អន់ចិត្ត តែក្រោយមកគាត់បានចុះចូល រៀនទទួល និងយកអ្វីដែលយើងបានហាមគាត់ ដោយព្រោះយើងស្រឡាញ់គាត់ យើងចង់ការពារគាត់។ នៅក្នុងចំណុចនេះអ្នកនិពន្ធក៏បានលើកតួអង្គក្នុងព្រះគម្ពីរមួយចំនួនផង ដែលបានបណ្តោយឲ្យកូនធ្វើតាមតែអំពើចិត្ត ដូចជាលោក អេលី គឺគាត់មិនបានស្តីបន្ទោសកូនរបស់គាត់ឡើយ ហើយក៏មិនបានហាមឃាត់ពួកគេដែរ គឺគាត់បានលើកកូនរបស់គាត់ខ្ពស់ជាងព្រះ ហើយនៅទីបញ្ចប់គាត់រស់នៅ ដើម្បីតែ

ឮកូនរបស់គាត់បានស្លាប់ក្នុងសមរភូមិប៉ុណ្ណោះ ហើយគាត់បានស្លាប់ទៅទាំងទុក្ខព្រួយ។ ស្តេច ដាវីឌ ក៏ដូចគ្នា បើយើងអានប្រវត្តិរបស់ទ្រង់ យើងឃើញកូនៗរបស់ទ្រង់រំលោភ កាប់សម្លាប់គ្នា បះបោរ អំនួតដណ្តើមរាជ្យបល្ល័ង្ក។ល។ ការទាំងនោះបានកើតឡើងដោយសារស្តេចបានបណ្តោយឲ្យបុត្ររបស់ទ្រង់ធ្វើតាមតែអំពើចិត្ត។

នៅក្នុងជំពូកទី១៤ «សូមបណ្តុះបណ្តាលពួកគេដោយនឹកចាំអំពីឥទ្ធិពលនៃគំរូរបស់លោកអ្នកផ្ទាល់ជានិច្ច» ការបណ្តុះបណ្តាលកូនៗចេញពីគំរូរបស់ឪពុកម្តាយគឺជាចំណុចសំខាន់ ចំណុចគ្រឹះទាំងឡាយក្នុងជីវិតរបស់ កូនៗយើងគួរតែមាននៅក្នុងជីវិតរបស់ឪពុកម្តាយជាមុន ដូចឃ្លាដែលគេច្រើនតែនិយាយ *«ស្លឹកឈើជ្រុះមិនដែលឆ្ងាយពីគល់»*។ ហើយកណ្ឌគម្ពីរ ម៉ាថាយ ៧:១៧ ក៏បានលើកឡើងដែរថា «ដូច្នេះអស់ទាំងដើមឈើល្អ តែងមានផ្លែល្អ ឯដើមអាក្រក់ ក៏តែងមានផ្លែអាក្រក់ដែរ»។ កូនៗរបស់យើង ពួកគាត់សង្កេតមើលការប្រព្រឹត្តិរបស់យើង គាត់រៀន ដោយភ្នែកលឿនជាងត្រចៀក។ ដូច្នេះ ចូរប្រយ័ត្ននូវអ្វីដែលយើងធ្វើនៅចំពោះមុខកូនៗ។ កូនៗរបស់យើងតែងតែចង់ធ្វើតាមគំរូយើង ហេតុដូច្នេះបានជាយើងគួរតែបណ្តុះនូវគំរូល្អៗ ដែលជួយដល់ពួកគេ។ ដូចជាការអានសៀវភៅអានព្រះគម្ពីរ ការជួយដល់អ្នកអត់ឃ្លាន អធិស្ឋានសម្រាប់អ្នកដទៃ។

សរុបមក ខ្ញុំចង់លើកទឹកចិត្តដល់អ្នកឪពុកម្តាយឲ្យបាននៅជាមួយកូនៗឲ្យបានច្រើន។ ឱឪពុកម្តាយទាំងអស់គ្នាអើយ ខ្ញុំក៏ធ្លាប់ជួប

ការបាក់ទឹកចិត្ត ការអស់សង្ឃឹម ការភ័យខ្លាច ការខឹង និងមិនចេះទប់អារម្មណ៍នៅក្នុងការចិញ្ចឹមកូនដែរ។ ប៉ុន្តែ ខ្ញុំបានបង្អង់ ហើយអធិស្ឋាន ដើម្បីឲ្យខ្ញុំអាចចេះអត់ធ្មត់ យឺតនឹងខឹងពួកគេ អាចគ្រប់គ្រងខ្លួនឯង និងរៀនយល់ពីកូនៗរបស់ខ្ញុំ ព្រោះពួកគេមិនដូចគ្នាទេ។ ជំនួយ និងកម្លាំងរបស់ខ្ញុំតែមួយគត់ គឺមកពីអង្គព្រះយេស៊ូវគ្រីស្ទ។ ខ្ញុំតែងតែប្រាប់ព្រះអង្គអំពីការនេះ ហើយខ្ញុំថ្វាយកូនរបស់ខ្ញុំទៅកាន់ព្រះជាម្ចាស់ និងបន្តបង្ហាត់បង្រៀនតាមការណែនាំរបស់ព្រះវិញ្ញាណបរិសុទ្ធ និងអ្វីដែលមាននៅក្នុងព្រះគម្ពីរ។

ខ្ញុំសូមលើកទឹកចិត្តឪពុកម្តាយទាំងអស់ឲ្យអានសៀវភៅនេះ ពីព្រោះមានចំណុចលម្អិតជាច្រើនក្នុងសៀវភៅនេះ ដែលយើងអាចយកមកអនុវត្តក្នុងការចិញ្ចឹមកូនៗរបស់យើង។

សូមព្រះប្រទានពរ!

លោកស្រី ហង្ស សោភ័ណ
— ប្រធានព័ន្ធកិច្ចវាលចម្រូត

សេចក្តីផ្តើម

«ចូរបង្ហាត់កូនក្មេង ឲ្យប្រព្រឹត្តតាមផ្លូវដែលគួរប្រព្រឹត្តនោះវានឹងមិនលះបង់ពីផ្លូវនោះដរាបដល់ចាស់» (សុភាសិត ២២:៦)។

ខ្ញុំគិតថាគ្រីស្ទបរិស័ទភាគច្រើនបានស្គាល់ប្រធានបទនៅខាងដើមទំព័រនេះហើយ។ ដែលជាសំឡេងហើយប្រហាក់ប្រហែលធ្លាប់ឮនៅត្រចៀករបស់យើងដូចជាបទចម្រៀងចាស់មួយ។ ប្រហែលជាលោកអ្នកបានស្តាប់ អាន និយាយ ឬបានដកស្រង់មកជាច្រើនដង។ តើពិតមែនទេ?

ប៉ុន្តែក្រោយមក តើខ្លឹមសារនៃអត្ថបទនេះត្រូវបានយកចិត្តទុកដាក់ប៉ុណ្ណាដែរ? គោលការណ៍របស់អត្ថបទនោះត្រូវបានគេស្គាល់តិចតួចណាស់។ ការអនុវត្តន៍ចំពោះមុខហាក់បីដូចជាមានការភ័យខ្លាចហើយយ៉ាងកម្រ។ ប្រិយមិត្តអ្នកអាន តើខ្ញុំមិននិយាយការពិតមែនឬ?

យើងមិនអាចនិយាយថា វាជាប្រធានបទថ្មីឡើយ។ ពិភពលោកមានវ័យចំណាស់ ហើយយើងមានបទពិសោធន៍ប្រហែលជាជិត៦ពាន់ឆ្នាំជាជំនួយដល់យើង។ យើងរស់នៅក្នុងសម័យកាលដែលមានការខិតខំប្រឹងប្រែងយ៉ាងខ្លាំង លើការអប់រំនូវគ្រប់វិស័យទាំងអស់។ យើងតែងតែឮថាមានសាលាថ្មីៗ ចាប់បើកដំណើរការនៅគ្រប់ទិសទី។ មានគេណែនាំពីប្រព័ន្ធសិក្សាថ្មីនិងសៀវភៅថ្មីគ្រប់ប្រភេទសម្រាប់យុវវ័យ និងកុមារ។ ហើយទោះបីយ៉ាងណាមានកុមារភាគច្រើនមិន

បានរៀននៅក្នុងផ្លូវដែលពួកគេគួរទទួលបាននោះទេ ហើយនៅពេលពួកគេធំពេញវ័យ ពួកគេមិនបានដើរនៅក្នុងផ្លូវរបស់ព្រះអម្ចាស់ឡើយ។

ឥឡូវនេះ តើយើងអាចពន្យល់ ឬយល់បែបណាពីស្ថានភាពនេះ? ហេតុដូច្នេះហើយ សេចក្តីពិតនោះគឺថា បទបញ្ញត្តរបស់ព្រះអម្ចាស់នៅក្នុងអត្ថបទរបស់យើងមិនបានបំពេញ នោះសេចក្តីសន្យារបស់ព្រះអង្គនៅក្នុងអត្ថបទនេះក៏មិនបានសម្រេចដែរ។

ប្រិយមិត្តអ្នកអានការទាំងអស់នេះប្រហែលជាធ្វើឲ្យមានការស្វែងរកយ៉ាងខ្លាំងនៅក្នុងចិត្ត។ សូមអនុញ្ញាតឲ្យមានពាក្យដាស់តឿនមកពីអ្នកបម្រើព័ន្ធកិច្ចអំពីការអប់រំដ៏ត្រឹមត្រូវសម្រាប់កុមារ។ ជឿខ្ញុំចុះ ប្រធានបទនេះគឺគួរតែជាអ្វីមួយដែលចូលទៅក្នុងគ្រប់មនសិការទាំងអស់ ហើយធ្វើឲ្យគ្រប់គ្នាសួរសំណួរមកកាន់ខ្លួនឯងថា «តើខ្ញុំកំពុងធ្វើអ្វីដែលខ្ញុំអាចធ្វើបានមែនឬ?»

នោះគឺជាប្រធានបទដែលផ្តោតលើស្ទើរតែទាំងអស់គ្នា ហើយស្ទើរតែគ្មានគ្រួសារណាមួយដែលមិនទទួលផលប៉ះពាល់ឡើយ។ ឪពុកម្តាយ គ្រូបង្រៀន អ៊ុំ ពូ មីង បងប្រុស បងស្រី គ្រប់គ្នាគឺមានចំណាប់អារម្មណ៍លើការនោះ។ ខ្ញុំគិតថា មានតិចតួចណាស់ដែលត្រូវបានរកឃើញថាជាអ្នកដែលមិនបានជះឥទ្ធិពលដល់ឪពុកម្តាយនៅក្នុងការគ្រប់គ្រងគ្រួសាររបស់គាត់ ឬជះឥទ្ធិពលដល់ការបណ្តុះបណ្តាលកុមារតាមរយៈការផ្តល់យោបល់ឬដំបូន្មាន។ ខ្ញុំគិតស្មានថា យើងគ្រប់គ្នា

អាចធ្វើអ្វីម្យ៉ាងនៅទីនេះ ទោះបីជាដោយផ្ទាល់ឬដោយប្រយោលក្តី ហើយខ្ញុំសូមដាស់តឿនដល់គ្រប់គ្នា ដើម្បីឲ្យចងចាំពីរឿងនេះ។

នោះក៏ជាប្រធានបទមួយ ដែលអ្នកពាក់ព័ន្ធទាំងអស់ស្ថិតក្នុងគ្រោះថ្នាក់យ៉ាងខ្លាំង នៃការខកខានបំពេញកាតព្វកិច្ចរបស់ខ្លួន។ នេះជាចំណុចសំខាន់ដែលមនុស្សយើងអាចងាយមើលឃើញកំហុសរបស់អ្នកជិតខាងបានច្បាស់ជាងកំហុសរបស់ខ្លួនឯង។ ជារឿយៗ ពួកគេនឹងចិញ្ចឹមកូនរបស់ខ្លួននៅក្នុងរបៀបដែលពួកគេបាននិយាយទៅកាន់មិត្តភក្តិរបស់ពួកគេថា មិនមានសុវត្ថិភាព។ ពួកគេបានមើលឃើញកម្ទេចនៅក្នុងភ្នែកនៃមនុស្សដទៃទៀត ហើយបានមើលរំលងធ្មឹមដែលនៅក្នុងភ្នែករបស់ខ្លួនឯង។ ពួកគេអាចមើលឃើញយ៉ាងឆាប់រហ័សដូចជាសត្វឥន្ទ្រី ក្នុងការចាប់កំហុសដែលនៅខាងក្រៅ ប៉ុន្តែពួកគេបានខ្វាក់ដូចជាសត្វប្រចៀវ ក្នុងការកត់សម្គាល់ពីបញ្ហាដែលកើតឡើងរាល់ថ្ងៃនៅក្នុងផ្ទះរបស់ខ្លួន។ ពួកគេឆ្លាតវៃចំពោះគ្រួសាររបស់បងប្អូនគេ ប៉ុន្តែល្ងង់ល្ងើចំពោះសាច់ញាតិខ្លួនឯង។ ទោះបីជានៅក្នុងគ្រួសាររបស់ខ្លួន ឬនៅទីណាក៏ដោយ យើងត្រូវតែប៉ាន់ប្រមាណលើការវិនិច្ឆ័យរបស់យើង។ ការនេះដែរ លោកអ្នកនឹងធ្វើវាបានល្អ ក្នុងការចងចាំរឿងនោះទុកក្នុងចិត្តគំនិតរបស់ខ្លួន។

ក្នុងនាមជាអ្នកបម្រើព្រះម្នាក់ ខ្ញុំអាចជួយកត់សម្គាល់ថា ស្ទើរតែគ្មានប្រធានបទណាមួយផ្សេងទៀតដែលមនុស្សយើងមើលទៅដូចជាតស៊ូខ្លាំងជាងប្រធានបទអំពីកូនៗរបស់ខ្លួនឡើយ។ ពេលខ្លះ ខ្ញុំមានការ

ងឿងឆ្ងល់ជាខ្លាំងចំពោះភាពយឺតយ៉ាវរបស់ឪពុកម្តាយគ្រីស្ទបរិស័ទ ក្នុងការទទួលស្គាល់ថាកូនរបស់គេមានកំហុសហើយសមនឹងទទួលការស្តីបន្ទោស។ មានមនុស្សមិនតិចនាក់ទេដែលខ្ញុំអាចនិយាយពីអំពើបាបរបស់ពួកគេផ្ទាល់ ប៉ុន្តែខ្ញុំពិបាកប្រាប់ថា កូនរបស់ពួកគេបានធ្វើខុសអ្វីមួយ។

សូមអញ្ជើញមកហើយអនុញ្ញាតឲ្យខ្ញុំបានដាក់បង្ហាញនៅចំពោះមុខលោកអ្នកនូវការណែនាំមួយចំនួនអំពីការបណ្តុះបណ្តាលដ៏ត្រឹមត្រូវ។ ព្រះវរបិតាព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធបានប្រទានពរដល់ពាក្យទាំងនោះហើយបានធ្វើឲ្យវាក្លាយជាពាក្យត្រូវតាមរដូវកាលដល់លោកអ្នកទាំងអស់គ្នា។ ការបដិធរាមិនមែនដោយព្រោះវាត្រង់ហើយសាមញ្ញ ហើយមើលងាយវាមិនមែនដោយព្រោះវាមិនមានអ្វីថ្មីឡើយ។ សូមឲ្យប្រាកដថា ប្រសិនបើលោកអ្នកនឹងបណ្តុះបណ្តាលក្មេងៗឲ្យបានទៅស្ថានសួគ៌ នោះវាគឺជាតម្រុយដែលមិនត្រូវទុកចោលដោយឡែកឡើយ។

ជំពូក១

បណ្តុះបណ្តាលគេនៅក្នុងរបៀបដែលគេត្រូវទទួល មិនមែនតាមរបៀបដែលពួកគេប្រាថ្នាចង់បានទេ

ស្មមចងចាំថា កូនក្មេងបានកើតមកជាមួយនឹងបំណងប្រាថ្នាលម្អៀងទៅរកការអាក្រក់ ហេតុនោះហើយប្រសិនបើលោកអ្នកអនុញ្ញាតឲ្យពួកគេជ្រើសរើសសម្រាប់ខ្លួនឯង នោះពួកគេប្រាកដជាជ្រើសរើសអ្វីដែលខុសជាមិនខាន។

ម្តាយមិនអាចដឹងឡើយថា កូនតូចរបស់គាត់ធំឡើងទៅជាយ៉ាងណា ខ្ពស់ឬទាប ខ្សោយឬខ្លាំង ឆ្លាតឬល្ងង់ទេ។ គាត់ប្រហែលជាអាចមានចំណុចទាំងនេះឬក៏អត់ វាមិនប្រាកដច្បាស់នោះទេ។ ប៉ុន្តែ មានចំណុចមួយដែលម្តាយអាចនិយាយយ៉ាងប្រាកដច្បាស់នោះគឺ គាត់មានចិត្តពុករលួយ និងបាប! វាគឺជារឿងធម្មតាទេ ដែលយើងជ្រើសរើសប្រព្រឹត្តអ្វីដែលខុស។ ស្តេចសាឡូម៉ូន មានបន្ទូលអំពីភាព «ល្ងង់ល្ងើ» ថាជា «សេចក្តីចម្កួតរមែងនៅជាប់ក្នុងចិត្តរបស់កូនក្មេង» (សុភាសិត ២២:១៥)។

«កូនណាដែលបណ្តោយអោយប្រព្រឹត្តតាមអំពើចិត្ត នោះតែងធ្វើឲ្យម្តាយមានសេចក្តីខ្មាសវិញ» សុភាសិត ២៩:១៥។ ចិត្តរបស់យើងគឺដូចជាដីដែលយើងដើរជាន់ទុកចោលហើយវាប្រាកដជានឹងដុះស្មៅ។

ដូច្នេះ ប្រសិនបើលោកអ្នកដោះស្រាយដោយវៃឆ្លាតជាមួយកូនរបស់លោកអ្នកនោះលោកអ្នកមិនត្រូវអនុញ្ញាតឲ្យគេធ្វើតាមអំពើចិត្តរបស់ពួកគេឡើយ។ គិត វិនិច្ឆ័យ ប្រព្រឹត្តសម្រាប់ពួកគេគឺដូចជាលោកអ្នកនឹងធ្វើសម្រាប់មនុស្សទន់ខ្សោយ ឬអ្នកពិការ។ ប៉ុន្តែ សម្រាប់ជាប្រយោជន៍នៃក្តីអាណិត កុំឲ្យតាមចំណង់ និងទំនោរខុសឆ្គងរបស់ពួកគេឡើយ។ វាមិនមែនដូចជាការប្រឹក្សាពីការចូលចិត្ត និងការប្រាថ្នារបស់ពួកគេឡើយ។ ពួកគេមិនទាន់ស្គាល់ពីអ្វីដែលល្អសម្រាប់គំនិត និងព្រលឹងរបស់ពួកគេ លើសតែអ្វីដែលល្អសម្រាប់តែខ្លួនប្រាណពួកគេឡើយ។ លោកអ្នកមិនគួរអនុញ្ញាតឲ្យគេសម្រេចថាត្រូវបរិភោគអ្វី ត្រូវផឹកអ្វី ហើយពីរបៀបដែលគេត្រូវតុបតែងខ្លួនឡើយ។ សូមខ្ជាប់ខ្ជួន ហើយដោះស្រាយជាមួយគំនិតរបស់គេនៅក្នុងរបៀបដូចគ្នាដែរ។ បណ្តុះបណ្តាលគេតាមរបៀបព្រះគម្ពីរហើយត្រឹមត្រូវនិងមិនមែនតាម បំណងប្រាថ្នារបស់គេ។

ប្រសិនបើលោកអ្នកមិនអាចយល់ពីគោលការណ៍ទី១ នៃការបណ្តុះបណ្តាលរបស់គ្រីស្ទបរិស័ទវានឹងគ្មានប្រយោជន៍អ្វីឡើ សម្រាប់លោកអ្នកក្នុងការអានបន្តទៅមុខទៀត។ ការចង់បានផ្ទាល់ខ្លួន គឺ

ស្នើរតែជារឿងដំបូងដែលលេចឡើងក្នុងគំនិតរបស់កុមារ ហើយវាក៏
ត្រូវតែជាជំហានដំបូងសម្រាប់លោកអ្នកក្នុងការទប់ទល់នឹងវាដែរ។

ជំពូក២

សូមបណ្តុះបណ្តាលកូនរបស់លោកអ្នកដោយ ភាពទន់ភ្លន់ ក្តីស្រឡាញ់ និងភាពអត់ធ្មត់

ខ្ញុំមិនមែនមានន័យថា លោកអ្នកធ្វើឲ្យកូនខូចឡើយ ប៉ុន្តែខ្ញុំមានន័យថា លោកអ្នកគួរតែឲ្យគេដឹងថា លោកអ្នកស្រឡាញ់គេ។ សេចក្តីស្រឡាញ់គួរតែជាខ្សែប្រាក់ដែលរត់ឆ្លងកាត់តាមរយៈគ្រប់ទាំងសកម្មភាព! សេចក្តីសប្បុរស ភាពស្លូតបូត ទ្រាំទ្រ អត់ធ្មត់ ចិត្តក្តួលអាណិត ការស្ម័គ្រចិត្តចូលទៅក្នុងបញ្ហា ការត្រៀមខ្លួនក្នុងការចូលរួមចំណែកក្នុងក្តីអំណររបស់កុមារ ទាំងនេះគឺជាគន្លឹះដែលក្មេងៗទទួលការដឹកនាំយ៉ាងងាយស្រួល ហើយជាតម្រុយដែលលោកអ្នកត្រូវតែធ្វើតាម ប្រសិនបើលោកអ្នកចង់រកផ្លូវចូលទៅក្នុងចិត្តគេឃើញ។

មានមនុស្សតិចណាស់ដែលបានរកឃើញ សូម្បីតែក្នុងចំណោមមនុស្សធំក្តី ក៏ពួកគេចូលចិត្តការលើកទឹកចិត្តជាងការបង្ខំដែរ។ វាមាននៅក្នុងគំនិតរបស់យើងគ្រប់គ្នានូវការទាស់ប្រឆាំង និងការបង្ខិតបង្ខំ។ យើងបានតម្រង់ខ្នងរបស់យើង ហើយពង្រឹងការបស់យើងទាស់ជាមួយគំនិតនៃការស្តាប់បង្គាប់ដោយបង្ខិតបង្ខំ។ យើង

ដូចជាសត្វសេះជំទង់នៅក្នុងដៃរបស់អ្នកបង្វឹក កាន់វាដោយថ្នមៗ ធ្វើវាឲ្យបានច្រើនលើកច្រើនសារ ហើយតាមរយៈការនោះ លោកអ្នកនឹងអាចដឹកវាដោយខ្សែបាន ហើយប្រើវាដោយតឹងរឹង នោះវានឹងត្រូវចំណាយពេលជាច្រើនខែ មុនពេលដែលលោកអ្នកអាចធ្វើជាម្ចាស់លើវាបាន។

ជាលទ្ធផល គំនិតរបស់ក្មេងៗក៏ត្រូវបានបង្កើតឡើងនៅក្នុងទម្រង់ដូចគ្នានឹងគំនិតរបស់យើងដែរ។ ភាពប្រិតប្រៀប និងភាពនឹងធឹងនៃអាកប្បកិរិយាអាចធ្វើឲ្យពួកគេត្រជាក់ចិត្តមកវិញ។ វានឹងរារាំងចិត្តរបស់ពួកគេ ហើយលោកអ្នកនឹងពិបាករកផ្លូវចូលឃើញ។ ប៉ុន្តែ ត្រូវឲ្យពួកគេដឹងថា លោកអ្នកមានអារម្មណ៍នៃសេចក្តីស្រឡាញ់ចំពោះពួកគេ ហើយលោកអ្នកពិតជាប្រាថ្នាចង់ធ្វើឲ្យពួកគេសប្បាយចិត្ត ហើយចង់ឲ្យពួកគេបានល្អ ហើយប្រសិនបើលោកអ្នកដាក់វិន័យដល់ពួកគេ គឺវាសម្រាប់ជាប្រយោជន៍ដល់ពួកគេ។ លោកអ្នកគួរតែឲ្យចង្វាក់បេះដូងរបស់លោកអ្នកបានហូរកាត់ព្រលឹងរបស់ពួកគេ អនុញ្ញាតឲ្យពួកគេបានឃើញការទាំងនេះ ខ្ញុំនិយាយយ៉ាងនេះថា ពួកគេនឹងក្លាយជាកម្មសិទ្ធរបស់លោកអ្នក។ ប៉ុន្តែ យើងត្រូវតែយកចិត្តពួកគាត់ដោយសេចក្តីសប្បុរសជាមុន បើយើងចង់ទទួលបានចំណាប់អារម្មណ៍របស់ពួកគាត់។

ហើយប្រាកដណាស់ ហេតុផលផ្ទាល់អាចនឹងបង្រៀនយើងនូវមេរៀននេះបាន។ កុមារ គឺជាភាវៈដែលទន់ខ្សោយ និងទន់ភ្លន់

ដូច្នេះហើយពួកគេត្រូវការការថែទាំដោយអត់ធ្មត់ និងដោយការយកចិត្តទុកដាក់។ យើងត្រូវតែណែនាំពួកគាត់ដោយយកចិត្តទុកដាក់យ៉ាងល្អិតល្អន់ដូចម៉ាស៊ីនទន់ខ្សោយ ក្រែងលោយើងប្រើម្រាមដៃគ្រឹមរបស់យើងនឹងបង្កគ្រោះថ្នាក់ច្រើនជាងទទួលផលល្អ។ ពួកគេដូចជារុក្ខជាតិទន់ខ្ចី ហើយត្រូវការការស្រោចទឹកយ៉ាងទន់ភ្លន់ ជាញឹកញាប់ប៉ុន្តែម្តងបន្តិចៗ។

យើងមិនត្រូវរំពឹងឲ្យការទាំងអស់កើតឡើងក្នុងពេលតែមួយបាននោះទេ។ យើងត្រូវដឹងថា កុមារជានរណា ដូច្នេះហើយយើងត្រូវបង្រៀនពួកគេតាមដែលពួកគេអាចទ្រាំទ្របាន។ គំនិតរបស់ពួកគេប្រៀបបាននឹងដុំដែក គឺមិនអាចដំ ហើយធ្វើឲ្យក្លាយជាមានប្រយោជន៍ក្នុងពេលតែមួយភ្លែតបានទេ ប៉ុន្តែអាចធ្វើបានដោយការដំបន្តិចម្តងៗតែប៉ុណ្ណោះ។ ការយល់ដឹងរបស់ពួកគេ គឺដូចជាដបមានកតូចចង្អៀត នោះយើងត្រូវចាក់ចំណេះដឹងបន្តិចម្តងៗ បើមិនដូច្នេះទេវានឹងត្រូវហៀរចេញ ហើយខាតបង់។ «ពីមួយឃ្លាទៅមួយឃ្លា ហើយពីការប្រៀនប្រដៅមួយលើការប្រៀនប្រដៅមួយទៀត ពីនេះបន្តិច ហើយពីនោះបន្តិច» ត្រូវតែជាច្បាប់របស់យើង។ ការសំលៀងលើថ្មបន្តិចម្តងៗប៉ុន្តែធ្វើវាជាទៀងទាត់ នោះវានឹងនាំឲ្យកណ្តៀវមានមុខមុតយ៉ាងល្អ។ ជាការពិតណាស់ វាទាមទារឲ្យមានការអត់ធ្មត់ក្នុងការបណ្តុះបណ្តាលក្មេង ព្រោះបើគ្មានការអត់ធ្មត់ នោះនឹងគ្មានលទ្ធផលឡើយ។

គ្មានអ្វីមកប៉ះប៉ូវជំនួសការអវត្តមាននៃភាពទន់ភ្លន់ និងសេចក្តី

ស្រឡាញ់ឡើយ! អ្នកបម្រើព័ន្ធកិច្ចអាចនឹងនិយាយការពិតដូច
ព្រះយេស៊ូវបានធ្វើយ៉ាងច្បាស់លាស់ ដោយមិនអាចតបតបាន ប៉ុន្តែ
ប្រសិនបើព្រះអង្គមិនបានមានបន្ទូលដោយមានសេចក្តីស្រឡាញ់នោះ
ទេ នោះនឹងមានព្រលឹងតិចតួចណាស់ដែលនឹងទទួលជឿលើទ្រង់។
ដូច្នេះ លោកអ្នកត្រូវតែកំណត់ចំពោះមុខកូនរបស់លោកអ្នកនូវ
កាតព្វកិច្ចរបស់ពួកគេ គឺការបង្គាប់បញ្ជា ការដាក់ពិន័យ ហើយនិង
ប្រាប់ហេតុផលដល់ពួកគេ។ ប៉ុន្តែ ប្រសិនបើខ្វះសេចក្តីស្រឡាញ់
នៅក្នុងការប្រព្រឹត្តរបស់លោកអ្នក នោះការងាររបស់លោកអ្នក
នឹងឥតប្រយោជន៍ទាំងអស់។ សេចក្តីស្រឡាញ់ជាអាថ៌កំបាំង
ដ៏អស្ចារ្យមួយនៃភាពជោគជ័យក្នុងការបណ្តុះបណ្តាល! កំហឹង
និងភាពកាចសាហាវអាចបង្កការភ័យខ្លាច ប៉ុន្តែវានឹងមិន
បញ្ចុះបញ្ចូលកូនថា លោកអ្នកត្រឹមត្រូវនោះទេ ហើយប្រសិនបើ
កូនឃើញជាញឹកញាប់ថា លោកអ្នកមានពេញដោយកំហឹង
នោះលោកអ្នកនឹងបាត់បង់នូវការគោរពពីកូនជាមិនខាន។
ឪពុកដែលនិយាយទៅកាន់កូនប្រុសរបស់ខ្លួនដូចដែល
លោក សូល បានធ្វើចំពោះយ៉ូណាថាន់(១សាំយូអែល ២០:៣០)
នោះមិនចាំបាច់រំពឹងថា នឹងរក្សាឥទ្ធិពលរបស់ខ្លួនលើគំនិតរបស់
កូនប្រុសនោះទេ។

សូមព្យាយាមយ៉ាងអស់ពីចិត្តក្នុងការរក្សាសេចក្តីស្រឡាញ់របស់
កូនលោកអ្នក។វាជារឿងគ្រោះថ្នាក់ដែលធ្វើឲ្យកូនៗរបស់លោកអ្នក

ខ្លាចលោកអ្នក។ អ្វីគ្រប់យ៉ាងសឹងតែប្រសើរជាងការបម្រុងទុក ហើយ
ការបង្ខិតបង្ខំរវាងលោកអ្នក និងកូនរបស់លោកអ្នក វានឹងនាំមកនូវ
ភាពភ័យខ្លាច។ ការភ័យខ្លាចនាំទៅរកការលាក់កំបាំង ការភ័យខ្លាច
ដូចជាសាបព្រោះគ្រាប់ពូជនៃការលាក់ពុត ហើយនាំទៅរកការកុហក
ជាច្រើន។ មានសេចក្តីពិតមួយនៅក្នុងពាក្យរបស់សាវ័ក ប៉ុល ទៅកាន់
ក្រុមជំនុំកូឡូសថា «ឪពុករាល់គ្នាអើយ កុំខុកជាន់កូនចៅឡើយ ក្រែង
វារសាយចិត្តចេញ»(កូឡូស ៣:២១)។ សូមកុំឲ្យមានការមើលរំលង
ចំពោះដំបូន្មាននេះឡើយ។

ជំពូក៣

សូមបណ្តុះបណ្តាលកូនរបស់លោកអ្នក ជាមួយជំនឿយ៉ាងខ្ជាប់ខ្ជួន ដោយការពឹងផ្អែក ភាគច្រើននៅលើលោកអ្នក

ព្រះគុណ គឺជាគោលការណ៍ដែលមានប្រសិទ្ធភាពជាងគោលការណ៍ណាៗទាំងអស់។ សូមមើលថា តើព្រះគុណមានការជះឥទ្ធិពលយ៉ាងណាខ្លះ? នៅពេលដែលព្រះគុណចូលមកក្នុងចិត្តរបស់លោកអ្នក តើរបៀបណាដែលព្រះគុណបានផ្តួលរំលំបន្ទាយរបស់សាតាំង គឺដោយរបៀបណាដែលវាធើភ្នំចេញ បំពេញជ្រលងភ្នំ ធ្វើឲ្យផ្លូវវៀចប្រែទៅជាត្រង់ ហើយផ្លាស់ប្រែមនុស្សឲ្យទៅជាថ្មីវិញ។ ពិតប្រាកដណាស់ គ្មានអ្វីមួយដែលមិនអាចទៅរួចជាមួយព្រះគុណឡើយ។

និស្ស័យបាបពិតជាខ្លាំង។ សូមមើលពីរបៀបដែលវាតស៊ូប្រឆាំងជាមួយអ្វីដែលទាក់ទងទៅនឹងនគរព្រះ—របៀបដែលវាប្រឆាំងនឹងរាល់ការប៉ុនប៉ង ដើម្បីឲ្យកាន់តែបរិសុទ្ធ។ របៀបដែលវាបន្តធ្វើសង្គ្រាមដោយឥតឈប់ឈរនៅក្នុងយើងរហូតដល់នាទីចុងក្រោយនៃជីវិត។

ប៉ុន្តែ បន្ទាប់ពីព្រះគុណ នោះប្រាកដជាគ្មានអ្វីដែលមានឥទ្ធិពល

ជាងការអប់រំនោះទេ។ ទម្លាប់ដំបូង (ប្រសិនបើខ្ញុំអាចនិយាយបាន) គឺជាអ្វីគ្រប់យ៉ាងជាមួយយើង នៅក្រោមអំណាចព្រះ។ យើងបានក្លាយជាយើងតាមរយៈការបណ្តុះបណ្តាលដែលយើងទទួលបានកាលយើងនៅជាក្មេង។ ចរិតលក្ខណៈរបស់យើងបានយកទម្រង់តាមការបំពាក់បំប៉ន ដែលយើងទទួលបានតាំងពីកុមារ។

លោក សេស៊ីល (Cecil) បានមានប្រសាសន៍ថា «បុគ្គលម្នាក់បានឃើញតែជីវិតតិចតួចតែប៉ុណ្ណោះ ប៉ុន្តែមិនបានឃើញកន្លែងនៃការអប់រំលើគំនិត និងទម្លាប់នៃការគិតរបស់មនុស្សប្រុស កុមារ ដែលនាំចេញមកពីថ្នាលដែលបង្ហាញនៅពេញមួយជីវិតរបស់ពួកគេ!»។

យើងពឹងផ្អែកយ៉ាងខ្លាំង លើអ្នកដែលមើលថែយើងកាលយើងនៅក្មេង។ យើងផ្តល់អោយពួកគាត់ នូវពណ៌ រសជាតិ ភាពលម្អៀងដែលនៅជាប់នឹងយើងច្រើន ឬតិចពេញមួយជីវិតរបស់យើងទៅក្មេងៗ។ ក្មេងចាប់យកភាសារបស់អ្នកមើលថែ និងម្តាយរបស់ពួកគេ ហើយរៀននិយាយតាមស្មើរតែមិនដឹងខ្លួន និងគ្មានការសង្ស័យ។ ក្មេងតូចៗបានចាប់យកអ្វីម្យ៉ាងនៃអាកប្បកិរិយារបស់ពីមនុស្សពេញវ័យ អំពីរបៀប ហើយនិងគំនិតនៅក្នុងពេលជាមួយគ្នា។ មានតែពេលវេលាប៉ុណ្ណោះដែលនឹងបង្ហាញរឿងរ៉ាវទាំងអស់នោះ ខ្ញុំសង្ស័យថា តើមនុស្សពេញវ័យទាំងអស់គ្នាជំពាក់ការចាប់អារម្មណ៍ពីសំណាក់កុមារច្រើនប៉ុណ្ណា? ហើយតើមានរឿងប៉ុន្មានក្នុងខ្លួនរបស់កុមារ ដែលអាចត្រូវបានតាមដានរហូតដល់គ្រាប់ពូជ ដែលបានសាបព្រោះក្នុង

ជំពូក៤

សូមបណ្តុះបណ្តាលជាមួយនឹងគំនិតនេះបន្ត ជានិច្ចនៅចំពោះមុខលោកអ្នកថា ព្រលឹង របស់កូនលោកអ្នក គឺជារឿងដំបូងដែលត្រូវ

ពិតជាគួរឲ្យស្រឡាញ់ គ្មានអ្វីគួរឲ្យចម្លែកទេ នោះគឺជាកូនតូចៗទាំងនេះនៅក្នុងភ្នែករបស់លោកអ្នក ប៉ុន្តែបើលោកអ្នកស្រឡាញ់គេ ចូរគិតពីព្រលឹងពួកគេឲ្យបានញឹកញាប់។ គ្មានកម្រៃណាមកប្រៀបស្មើសម្រាប់លោកអ្នកដូចជាកម្រៃនៃជីវិតអស់កល្បរបស់ពួកគេឡើយ។ គ្មានផ្នែកណាមួយនៃពួកគេ ដែលសំខាន់មកកាន់លោកអ្នកជាជាងព្រលឹង ដែលមិនចេះស្លាប់របស់ពួកគេឡើយ។ ពិភពលោកជាមួយនឹង ភាពស្រស់ស្អាតរបស់វា នឹងកន្លងផុតទៅ ភ្នំទាំងឡាយនឹងរលាយទៅ ហើយផ្ទៃមេឃក៏នឹងត្រូវមូរដូចជាក្រាំង ព្រះអាទិត្យនឹងលែងភ្លឺ។ ប៉ុន្តែ វិញ្ញាណដែលស្ថិតនៅក្នុងកូនតូចៗដែលជាទីស្រឡាញ់របស់លោកអ្នកទាំងនោះនឹងរស់រានមានជីវិតទាំងអស់គ្នា ហើយទោះជាមានសុភមង្គល ឬទុក្ខព្រួយ (និយាយតាមបែបជាមនុស្ស) នោះគឺអាស្រ័យទាំងស្រុងលើលោកអ្នក។ នេះជាគំនិត ដែលលោកអ្នកគួរគិតឲ្យបានខ្ពស់បំផុតក្នុងគ្រប់ការដែល

លោកអ្នកធ្វើ ដើម្បីកូនៗរបស់ខ្លួន។ នៅគ្រប់ជំហានដែលលោកអ្នកធ្វើសម្រាប់ពួកគេ គ្រប់ផែនការ និងគម្រោងការណ៍ និងការរៀបចំដែលទាក់ទងនឹងពួកគេ សូមកុំរំលងសំណួរដ៏សំខាន់នេះគឺថា «តើវានឹងប៉ះពាល់ដល់ព្រលឹងរបស់ពួកគេយ៉ាងដូចម្តេច?»

សេចក្តីស្រឡាញ់ចំពោះព្រលឹងកូនរបស់លោកអ្នកគឺមានខ្លឹមសារលើសសេចក្តីស្រឡាញ់ណាស់ណាទាំងអស់។ ការចិញ្ចឹមកូនដោយមានការលួងលោម និងការបណ្តោយកូនរបស់លោកអ្នកក្នុងលក្ខណៈដូចជាថា ពិភពលោកនេះគឺជាអ្វីដែលគាត់ត្រូវស្វែងរក ហើយជីវិតនេះជារដូវកាលតែមួយគត់សម្រាប់សុភមង្គល ការធ្វើបែបនេះមិនមែនជាសេចក្តីស្រឡាញ់ពិតទេ ប៉ុន្តែជាភាពឃោរឃៅ ហើយវាគឺជាការដែលប្រព្រឹត្តទៅលើពួកគាត់ដូចជាសត្វមួយដែលមាននៅលើផែនដី។ ហើយមានផែនដីតែមួយសម្រាប់ការរំពឹងទុក ដោយគ្មានអ្វីបន្ទាប់ពីការស្លាប់នោះឡើយ។ វាគឺជាការលាក់បាំងពីគាត់នូវការពិតដ៏អស្ចារ្យ ដែលពួកគេគួរតែរៀនតាំងពីកុមារភាពថា ចុងបញ្ចប់នៃជីវិតរបស់ពួកគេ គឺជាការសង្គ្រោះនៃព្រលឹងរបស់ពួកគាត់ដោយព្រះអម្ចាស់។

គ្រីស្ទបរិស័ទពិត ប្រសិនបើគាត់នឹងបណ្តុះបណ្តាលកូនៗរបស់គាត់សម្រាប់នគរស្ថានសួគ៌នោះមិនត្រូវអប់រំកូនៗអោយធ្វើជាទាសកររបស់ភាពឡូយឆាយទេ។ គាត់មិនត្រូវណែនាំអោយកូនៗអោយទទួលយករឿងឡូយឆាយ តាមទម្លាប់របស់លោកិយ ដែលគេបាន

បង្រៀនកូនៗរបស់គេទេ ប៉ុន្តែត្រូវណែនាំពួកគេតាមរបៀបជាក់លាក់
អំពីភាពគ្រោះថ្នាក់នៃភាពឡូយឆាយ។ ត្រូវអនុញ្ញាតឲ្យពួកគេអាន
សៀវភៅដែលមានចម្ងល់ ហើយអនុញ្ញាតឲ្យពួកគេបង្កើតទម្លាប់ទៅរក
ទំនោរនៃការសង្ស័យ។ ឪពុកម្តាយត្រូវតែបណ្តុះបណ្តាលដោយភ្នែក
មើលទៅព្រលឹងកូនៗរបស់គាត់។ គាត់មិនត្រូវខ្មាសក្នុងការស្តាប់ឮ
អ្នកដទៃនិយាយថា ការបណ្តុះបណ្តាលរបស់គាត់មានតែមួយ និង
ចម្លែកជាងគេនោះទេ។ ចុះបើវាដូច្នោះមែន? ពេលវេលាគឺខ្លីណាស់
ភាពពេញនិយម ភាពឡូយឆាយនៃពិភពលោកនេះនឹងកន្លងផុត
ទៅ។ អ្នកដែលបានបង្ហាត់កូនរបស់ខ្លួនសម្រាប់ស្ថានសួគ៌ជាជាង
សម្រាប់ផែនដី គឺសម្រាប់ព្រះ ជាជាងសម្រាប់មនុស្ស នៅទីបំផុត
គាត់គឺជាឪពុកម្តាយដែលគ្រប់គ្នាហៅថា ជាអ្នកមានប្រាជ្ញា។

សូមបណ្តុះបណ្តាលកូនរបស់លោកអ្នក អំពីចំណេះដឹងនៃព្រះគម្ពីរ

ខ្ញុំជឿថា លោកអ្នកមិនអាចធ្វើឲ្យកូនរបស់លោកអ្នកស្រឡាញ់ព្រះគម្ពីរបានទេ។ ប៉ុន្តែ ព្រះវិញ្ញាណបរិសុទ្ធអាចប្រទានឲ្យយើងមានចិត្តរីករាយនៅក្នុងព្រះបន្ទូល។ ប៉ុន្តែ លោកអ្នកអាចធ្វើឲ្យកូនរបស់លោកអ្នកស្គាល់ព្រះគម្ពីរ ហើយលោកអ្នកត្រូវប្រាកដថា កុំបង្ខំពួកគេឲ្យឆាប់ស្គាល់ព្រះគម្ពីរពេក ឬក៏ឲ្យចេះខ្លាំងពេកដែរ។

ចំណេះដឹងដ៏ជ្រាលជ្រៅអំពីព្រះគម្ពីរ គឺជាមូលដ្ឋានគ្រឹះនៃសេចក្តីជំនឿ។ បុគ្គលណាដែលមានមូលដ្ឋានគ្រឹះល្អ នោះជាទូទៅនឹងមិនក្លាយជាអ្នករវើរវាយ ហើយត្រូវបក់បោកដោយគ្រប់ទាំងខ្យល់នៃគោលលទ្ធិថ្មីឡើយ។ ការបណ្តុះបណ្តាលណាមួយដែលមិនបានបង្រៀនអំពីចំណេះដឹងព្រះគម្ពីរជាទីមួយ នោះគឺគ្មានសុវត្ថិភាព និងមិនត្រឹមត្រូវឡើយ។

លោកអ្នកត្រូវតែប្រុងប្រយ័ត្ននៅត្រង់ចំណុចនេះ ព្រោះអារក្សធ្វើការនៅច្រើនកន្លែង ហើយយើងងាយនឹងធ្វើអ្វីដែលមិនត្រឹមត្រូវ។ អ្នកខ្លះក្នុងចំណោមយើងបានផ្តល់កិត្តិយសដល់ក្រុមជំនុំ ជាងដល់ព្រះយេស៊ូវគ្រីស្ទដែលមានតែទ្រង់សក្តិសមនឹងទទួល។ ហើយអ្នកខ្លះ

ត្រូវរកឃើញតាមរបៀបនៃអាកប្បកិរិយា ដែលគោរពដល់សៀវភៅនៃ
ការបង្រៀនពីសាសនាច្រើនជាងព្រះគម្ពីរ ឬបំពេញចិត្តរបស់កូនៗ
ពួកគេ ដោយសៀវភៅរឿងតូចតាចជំនួសឲ្យព្រះគម្ពីរនៃសេចក្តីពិត។
ប៉ុន្តែ ប្រសិនបើលោកអ្នកស្រឡាញ់កូនរបស់លោកអ្នក ចូរឲ្យព្រះគម្ពីរ
ជាអ្វីគ្រប់យ៉ាងនៅក្នុងការបណ្តុះបណ្តាលព្រលឹងវិញ្ញាណរបស់
ពួកគេ។ ហើយទុកឲ្យសៀវភៅផ្សេងៗទាំងអស់ ចុះទៅយកកន្លែង
ទីពីរវិញ។

កុំខ្វល់ខ្វាយច្រើនពេក ក្នុងការឆ្លើយសំណួរ-ចម្លើយរបស់ពួកគេ
ឡើយ (ដូចជានៅក្នុងសៀវភៅ «ទីក្រុងថ្មី៖ ៥២សំណួរ&ចម្លើយ
សម្រាប់ចិត្ត&គំនិត») ព្រោះថាពួកគេមានភាពខ្លាំងក្នុងការចាំអំពី
ព្រះគម្ពីរ។ សូមជឿខ្ញុំចុះថា នេះជាការបង្ហាត់បង្រៀនដែល ព្រះនឹង
ទទួលនូវការគោរព។ នៅក្នុងលើកឡើងអំពីទ្រង់ថា «ដ្បិតទ្រង់បាន
តម្កើងព្រះបន្ទូលទ្រង់ ឲ្យធំលើសព្រះនាមទ្រង់ទៅទៀត»(ទំនុកតម្កើង
១៣៨:២) ហើយខ្ញុំគិតថា ទ្រង់ប្រទានពរជ័យពិសេសមួយដល់
អស់អ្នកដែលព្យាយាមលើកតម្កើងព្រះបន្ទូលក្នុងចំណោមមនុស្ស។

សូមសង្កេតមើលថា តើកូនរបស់លោកអ្នកអានព្រះគម្ពីរដោយ
ការគោរពឬអត់? បង្ហាត់ពួកគេឲ្យចេះមើលទៅព្រះបន្ទូល មិនមែន
ដូចជាពាក្យរបស់មនុស្សទេ ប៉ុន្តែដោយសារព្រះបន្ទូលនៃព្រះជា
សេចក្តីពិត ដែលបានតែងឡើងដោយព្រះវិញ្ញាណបរិសុទ្ធផ្ទាល់
ទាំងអស់ជាសេចក្តីពិត មានគ្រប់ទាំងប្រយោជន៍ ហើយអាចធ្វើឲ្យ

យើងមានប្រាជ្ញាទៅរកសេចក្តីសង្គ្រោះតាមរយៈជំនឿ ដែលនៅក្នុង
ព្រះគ្រីស្ទយេស៊ូវ។

សូមមើលថា តើពួកគេអានព្រះបន្ទូលជាប្រចាំឬអត់? បង្ហាត់ពួកគេ
ឲ្យចាត់ទុកព្រះបន្ទូលថាជាអាហារប្រចាំថ្ងៃសម្រាប់ព្រលឹងវិញ្ញាណ
របស់ពួកគេ និងជារបស់ចាំបាច់សម្រាប់សុខភាពប្រចាំថ្ងៃរបស់
ព្រលឹងវិញ្ញាណពួកគេ។ ខ្ញុំដឹងច្បាស់ណាស់ថា លោកអ្នកមិនអាចប
ង្កើតអ្វីលើសពីទម្រង់បានទេ។ ប៉ុន្តែ មិនមានការប្រាប់អំពីចំនួននៃ
អំពើបាប ដែលទម្រង់ណាមួយគ្រាន់តែអាចរារាំងដោយប្រយោល
ប៉ុណ្ណោះ។

មើលថាពួកគេអានទាំងអស់ឬអត់? លោកអ្នកមិនត្រូវបារម្ភក្នុងការ
នាំយកគោលលទ្ធិណាមួយមកចំពោះមុខពួកគេឡើយ។ លោកអ្នក
មិនចាំបាច់បារម្ភថាគោលលទ្ធិចម្បងគេនៃក្រុមជំនុំជារឿងដែលកុមារ
មិនអាចយល់បានទេ។ កុមារអាចយល់ពីព្រះគម្ពីរ ច្រើនលើសជាង
យើងគិតទៅទៀត។

ប្រាប់ពួកគេពីអំពើបាប ទោសកំហុស លទ្ធផល អំណាច និង
ភាពឃោរឃៅរបស់អំពើបាប។ លោកអ្នកនឹងរកឃើញថាពួកគេ
អាចយល់អ្វីមួយអំពីការទាំងនេះ។

សូមប្រាប់ពួកគេអំពីព្រះអម្ចាស់យេស៊ូវគ្រីស្ទ និងកិច្ចការដែលទ្រង់
ធ្វើសម្រាប់សេចក្តីសង្គ្រោះរបស់យើង—ការធួននឹងបាប ឈើឆ្កាង
ព្រះលោហិត យញ្ញបូជា ការទទួចអង្វរជំនួស។ សាកធ្វើបែបនេះ
លោកអ្នកនឹងរកឃើញថា ទាំងអស់នេះគ្មានអ្វីមួយដែលហួសពី

ការយល់ដឹងពួកគេឡើយ។

សូមប្រាប់ពួកគេអំពីកិច្ចការនៃព្រះវិញ្ញាណបរិសុទ្ធ ដែលគង់នៅក្នុងចិត្តរបស់មនុស្ស និងរបៀបដែលទ្រង់ផ្លាស់ប្តូរ កែជាថ្មីឡើងញែកចេញជាបរិសុទ្ធ និងបន្សុទ្ធ—លោកអ្នកនឹងឃើញភ្លាមៗថាពួកគេអាចទៅជាមួយលោកអ្នក នៅក្នុងកម្រិតណាមួយនៅក្នុងរឿងនេះ។

សរុបមក ខ្ញុំគិតថាយើងមិនដឹងថា តើក្មេងតូចម្នាក់អាចទទួលយកបាននូវប្រវែងបណ្តោយ និងទទឹងនៃដំណឹងល្អដ៏រុងរឿងកម្រិតណាទេ។ ប៉ុន្តែ ពួកគេមើលឃើញរឿងទាំងនេះច្រើនជាងយើងគិតទៅទៀត។

ចំពោះអាយុដែលការណែនាំខាងសេចក្តីជំនឿរបស់កុមារគួរចាប់ផ្តើម នោះគ្មានច្បាប់ទូទៅអាចត្រូវបានគេដាក់ចេញឡើយ។ ចិត្តរបស់កុមារខ្លះ ហាក់បើកចំហលឿនជាងកុមារខ្លះទៀត។ យើងកម្រ ដែលថាចាប់ផ្តើមលឿនពេកណាស់។ មានគំរូដ៏អស្ចារ្យនៅក្នុងកំណត់ត្រាអំពីអ្វីដែលកុមារអាចទទួលបាន គឺសូម្បីតែនៅអាយុបីឆ្នាំក៏ដោយគេអាចដឹងបាន។

សូមបំពេញគំនិតរបស់ពួកគេដោយព្រះបន្ទូល។ សូមឲ្យព្រះបន្ទូលគង់នៅក្នុងពួកគេយ៉ាងបរិបូណ៌។ ផ្តល់ឲ្យពួកគេនូវព្រះគម្ពីរ គឺព្រះគម្ពីរទាំងមូល ទោះបីជាពួកគេនៅក្មេងក៏ដោយ។

ជំពូក៦

សូមបណ្តុះបណ្តាលគេឲ្យមានទម្លាប់នៃការអធិស្ឋាន

ការអធិស្ឋាន គឺជាដង្ហើមជីវិតនៃសេចក្តីជំនឿពិត។ វាជាភស្តុតាងចម្បងមួយដែលបង្ហាញថា មនុស្សបានកើតជាថ្មី។ ព្រះអម្ចាស់មានបន្ទូលទៅកាន់លោក សុល ថា៖ «មើល» នៅថ្ងៃដែលទ្រង់បានចាត់បញ្ជូនលោក អាន៉ានាស ឲ្យទៅឯគាត់ «ដ្បិតមើល គាត់កំពុងតែអធិស្ឋាន»(កិច្ចការ ៩:១១)។ គាត់បានចាប់ផ្តើមអធិស្ឋាន ហើយនោះជាភស្តុតាងគ្រប់គ្រាន់ហើយ។

ការអធិស្ឋាន គឺជាសញ្ញាសម្គាល់នៃប្រជារាស្ត្ររបស់ព្រះអម្ចាស់នៅក្នុងថ្ងៃដែលចាប់ផ្តើមមានការបំបែករវាងពួកគេ និងពិភពលោក។ «ហើយនៅជាន់នោះ គេចាប់តាំងអំពាវនាវដល់ព្រះនាមព្រះយេហូវ៉ា» (លោកុប្បត្តិ ៤:២៦)។

ការអធិស្ឋាន គឺជាលក្ខណៈសម្គាល់នៃគ្រីស្ទបរិស័ទពិតប្រាកដ។ ពួកគេអធិស្ឋាន—ដោយសារពួកគេទូលប្រាប់ព្រះអំពីតម្រូវការ អារម្មណ៍ បំណងប្រាថ្នា ការភ័យខ្លាចរបស់ពួកគេ ហើយទូលទៅកាន់

ព្រះអង្គដោយចេញពីចិត្ត។ គ្រីស្ទបរិស័ទដែលមានតែឈ្មោះ អាចនឹងអធិស្ឋានដដែលៗ ហើយក៏អធិស្ឋានបានល្អដែរ ប៉ុន្តែគាត់មិនអាចទៅលើសនោះបានទេ។

ការអធិស្ឋាន គឺជាចំណុចរបត់នៅក្នុងព្រលឹងរបស់មនុស្ស។ ព័ន្ធកិច្ចរបស់យើងគ្មានប្រយោជន៍ ហើយការងាររបស់យើងក៏ឥតប្រយោជន៍ដែរ រហូតទាល់តែអ្នករាល់គ្នាលុតជង្គង់ចុះ មិនមែនរហូតទាល់តែដល់ដំណាក់កាលចុងក្រោយនោះទេ បើធ្វើដូច្នេះនោះយើងគ្មានសង្ឃឹមលើសេចក្តីអធិស្ឋានឡើយ។

ការអធិស្ឋានគឺជាអាថ៌កំបាំងដ៏អស្ចារ្យមួយនៃភាពចម្រុងចម្រើនខាងឯវិញ្ញាណ។ ពេលមានការរួមប្រកបជាលក្ខណៈផ្ទាល់ខ្លួនជាមួយព្រះនោះព្រលឹងលោកអ្នកនឹងរីកដូចស្មៅក្រោយភ្លៀង។ នៅពេលដែលមានការអធិស្ឋានតិចតួច គ្រប់ទាំងអស់នឹងនៅស្ងៀម ហើយលោកអ្នកស្ទើរតែមិនអាចរក្សាព្រលឹងរបស់លោកអ្នកឲ្យនៅរស់ផង។ ចំពោះគ្រីស្ទបរិស័ទដែលកំពុងរីកចម្រើន គ្រីស្ទបរិស័ទជឿនទៅមុខគ្រីស្ទបរិស័ទដ៏រឹងមាំ នោះខ្ញុំប្រាកដថា ពួកគាត់គឺជាមនុស្សម្នាក់ដែលនិយាយជាមួយព្រះអម្ចាស់របស់គាត់ជាញឹកញាប់។ គាត់ទូលអង្វរច្រើន ហើយគាត់ទទួលបានការឆ្លើយតបច្រើន តាមព្រះទ័យទ្រង់។ គាត់ទូលប្រាប់ព្រះយេស៊ូវនូវអ្វីគ្រប់យ៉ាង ហេតុដូច្នេះគាត់តែងតែដឹងពីរបៀបដែលត្រូវប្រព្រឹត្ត។ ការអធិស្ឋាន គឺជាធនធានដ៏ខ្លាំងបំផុត ដែលព្រះបានដាក់នៅក្នុងដៃរបស់យើង។ វាជាអាវុធដ៏ល្អបំផុតក្នុងការប្រើ

គ្រប់ការលំបាក ហើយជាមធ្យោបាយដោះស្រាយដ៏ប្រាកដប្រជាបំផុត ក្នុងគ្រប់បញ្ហា។ វាជាកូនសោដែលបើកកន្លែងរក្សាទុករបស់មានតម្លៃ នៃការសន្យា និងជាដៃដែលនាំមកនូវព្រះគុណ និងជាជំនួយក្នុង ពេលមានតម្រូវការ។គឺជាត្រែដែលព្រះបានបញ្ជាយើងឲ្យបន្លឺឡើង ក្នុងគ្រប់ការចាំបាច់របស់យើង ហើយវាជាសំឡេងដែលទ្រង់បាន សន្យាថា នឹងស្តាប់ជានិច្ច គឺដូចជាម្តាយដែលតែងចង់ស្តាប់សំឡេង របស់កូនៗរបស់ខ្លួនដែរ។

ការអធិស្ឋាន គឺជាមធ្យោបាយសាមញ្ញបំផុតដែលមនុស្សអាចប្រើ ក្នុងការចូលមករកព្រះ។ វាស្ថិតនៅក្នុងការឈានទៅដល់មនុស្ស ទាំងអស់គ្នា—អ្នកជម្ងឺ មនុស្សចាស់ ជនពិការ មនុស្សខ្វិន មនុស្ស ខ្វាក់ អ្នកក្រ អ្នកមិនបានរៀនសូត្រ—ទាំងអស់គ្នាអាចអធិស្ឋាន បាន។ លើសពីការអង្វរចំពោះភាពខ្វះខាត ការខ្វះលទ្ធភាព ក្នុង ការរៀនសូត្រ កង្វះសៀវភៅ និងកង្វះអាហារូបករណ៍ នោះលោកអ្នក អាចទូលអង្វរ សូមព្រះអង្គថែរក្សា ព្រលឹងវិញ្ញាណរបស់លោកអ្នកផង ដែរ។ ព្រះបន្ទូលបានចែងថា «តែមិនបានអ្វីសោះ ពីព្រោះមិនសូម» (យ៉ាកុប ៤:២) នឹងក្លាយជាការថ្កោលទោសដ៏គួរឲ្យខ្លាចចំពោះ មនុស្សជាច្រើននៅថ្ងៃជំនុំជម្រះ។

ឪពុកម្តាយទាំងឡាយអើយ ប្រសិនបើលោកអ្នកស្រឡាញ់កូន ចូរធ្វើអ្វីៗទាំងអស់ដែលស្ថិតនៅក្នុងអំណាចរបស់លោកអ្នក ដើម្បី បង្ហាត់ពួកគេឲ្យមានទម្លាប់នៃការអធិស្ឋាន។ បង្ហាញពួកគេពីរបៀប

ចាប់ផ្តើម។ ប្រាប់ពួកគេពីអ្វីដែលត្រូវនិយាយ។ លើកទឹកចិត្តពួកគេឲ្យ តស៊ូ។ រម្លឹកពួកគេ ប្រសិនបើពួកគេធ្វេសប្រហែស និងខ្ជិលច្រអូស។ ទោះក្នុងកាលៈទេសៈណាក៏ដោយ កុំឲ្យវាក្លាយជាកំហុសរបស់លោក អ្នក ប្រសិនបើគេមិនដែលអំពាវនាវដល់ព្រះនាមរបស់ព្រះអម្ចាស់។

សូមចាំថា នេះជាជំហានដំបូងក្នុងជំនឿដែលកុមារអាចទទួល យកបាន។ រយៈពេលការចំណាយពេលយ៉ាងយូរមុនពេលគាត់អាច អាន លោកអ្នកអាចបង្រៀនគាត់ឲ្យលុតជង្គង់នៅក្បែរម្តាយរបស់គាត់ ហើយនិយាយពាក្យសាមញ្ញៗនៃការអធិស្ឋាន និងបទសរសើរដែល ម្តាយបានដាក់ក្នុងមាត់របស់កូន។ ដោយសារជំហានដំបូងក្នុងកិច្ចការ ណាមួយ គឺតែងតែមានសារៈសំខាន់បំផុត។ ដូច្នេះហើយបានជារបៀ បនៃការអធិស្ឋានរបស់កូនលោកអ្នក គឺជាចំណុចមួយដែលសមនឹង ទទួលបាននូវការយកចិត្តទុកដាក់បំផុតអំពីលោកអ្នក។ មានមនុស្ស តិចណាស់ ដែលដឹងគិតលើរឿងនេះ។ លោកអ្នកត្រូវប្រយ័ត្នក្រែង ពួកគេធ្លាក់ទៅក្នុងរបៀបនៃការនិយាយ ដោយប្រញាប់ប្រញាល់ ធ្វេសប្រហែស និងដោយមិនគោរព។ លោកអ្នកត្រូវតែប្រយ័ត្នចំពោះ ការធ្វេសប្រហែសលើ ការត្រួតពិនិត្យ ចំពោះបញ្ហានេះ ។ ដោយជួន កាល លោកអ្នកបញ្ជូនកូនទៅ អ្នកមើលថែ ឬទុកចិត្តកូនរបស់ លោកអ្នកខ្លាំងពេក ក្នុងការដែលទុកឲ្យគេធ្វើដោយខ្លួនឯង។ ខ្ញុំមិន អាចសរសើរម្តាយ ដែលមិនមើលថែរក្សាផ្នែកដ៏សំខាន់បំផុតនេះនៃ ជីវិតប្រចាំថ្ងៃរបស់កូនខ្លួនឯងនោះឡើយ។ ប្រាកដណាស់ ប្រសិនបើ មានទម្លាប់ណាមួយដែលដៃ និងភ្នែករបស់លោកអ្នកទាំងគូរអាចជួយ

បាននោះគឺជួយក្នុងការបង្កើត ទម្លាប់នៃការអធិស្ឋាន។

ជឿខ្ញុំចុះ ប្រសិនបើលោកអ្នកមិនដែលឮកូនរបស់លោកអ្នក អធិស្ឋានខ្លួនឯងទេ លោកអ្នកត្រូវ គិតឡើងវិញ។ បើបែបនោះ លោកអ្នកសូមមើលទៅ បក្សីដែលរៀបរាប់ក្នុងកណ្ឌគម្ពីរ យ៉ូប ទៅទៀត «វាពងចោលនៅលើដី ក៏បង្គប់ពងឲ្យក្តៅដោយសារខ្សាច់ ដោយឥតនឹកថា ជើងគេនឹងជាន់បំបែកបង់ ឬសត្វព្រៃណានឹងជាន់ឈ្លី ទៅទេ វាទុរជនចំពោះកូន ដូចជាមិនមែនរបស់ខ្លួនទេ ហើយដែលវាពងជាឥតប្រយោជន៍នោះ ក៏មិនរវល់ផង»(យ៉ូប ៣៩:១៤-១៦)។

ការអធិស្ឋាន គឺជាទម្លាប់មួយដែលយើងនឹកចាំបានយូរបំផុត។ មានបុរសសក់ស្កូវជាច្រើន អាចប្រាប់លោកអ្នកអំពីរបៀបដែលម្តាយគាត់ធ្លាប់ឲ្យគាត់អធិស្ឋានក្នុងវ័យកុមាររបស់គាត់។ ក្រុមជំនុំដែលគាត់ត្រូវបាននាំទៅថ្វាយបង្គំ អ្នកបម្រើព័ន្ធកិច្ចដែលគាត់បានឮការអធិប្បាយដៃគូដែលធ្លាប់លេងជាមួយគាត់ ទាំងអស់នេះប្រហែលជាបានកន្លងផុតពីការចងចាំរបស់គាត់ហើយ ដោយមិនបានបន្សល់ទុកស្លាកស្នាមអ្វីឡើយ។ ប្រហែលជារឿងផ្សេងទៀតបានកន្លងផុតពីគំនិតរបស់គាត់ ប៉ុន្តែជាញឹកញាប់លោកអ្នកនឹងឃើញថា គាត់នៅតែនឹកចាំអំពី ការអធិស្ឋានដំបូងរបស់គាត់។ ជារឿយៗ គាត់នឹងអាចប្រាប់លោកអ្នកពីកន្លែងដែលគាត់បានលុតជង្គង់ ហើយអ្វីដែលគាត់ត្រូវបានបង្រៀនឲ្យនិយាយ និងសូម្បីតែរបៀបដែលម្តាយរបស់គាត់មើលនៅពេលវេលានោះ។ វានឹងលេចឡើងមកដូចថ្មីនៅចំពោះមុខ

របស់គាត់ ដូចជាវាគឺបានកើតឡើង ទើបតែពីម្សិលមិញនៅឡើយ។

ប្រិយមិត្តអ្នកអាន ប្រសិនបើលោកអ្នកស្រឡាញ់កូនរបស់លោកអ្នក ខ្ញុំទូន្មានលោកអ្នកកុំបណ្តោយឲ្យពេលវេលានៃទម្លាប់ក្នុងការអធិស្ឋាន បានកន្លងហួសទៅដោយមិនដឹងខ្លួននោះឡើយ។ ប្រសិនបើលោកអ្នក បណ្តុះបណ្តាលកូនលោកអ្នកទៅលើរឿងអ្វីមួយ នោះសូមលោកអ្នក បង្ហាត់បង្រៀនគេឲ្យមានទម្លាប់នៃការអធិស្ឋាន។

ជំពូក៧

សូមបង្ហាត់បង្រៀនពួកគេឲ្យមានទម្លាប់ឧស្សាហ៍ព្យាយាម ហើយមានភាពទៀងទាត់ក្នុងការចូលរួមនៅក្នុងក្រុមជំនុំ

សូមប្រាប់ពួកគេអំពីកាតព្វកិច្ច និងឯកសិទ្ធិនៃការទៅក្រុមជំនុំនៃព្រះ ហើយចូលរួមក្នុងការអធិស្ឋានក្នុងក្រុមជំនុំ។ សូមប្រាប់ពួកគេនៅកន្លែងណាក៏ដោយ ដែលរាស្ត្ររបស់ព្រះអម្ចាស់បានប្រមូលផ្តុំគ្នានៅទីនោះ ព្រះអម្ចាស់យេស៊ូវមានវត្តមាននៅក្នុងលក្ខណៈពិសេស ហើយថាអ្នកដែលអវត្តមានខ្លួនឯងគឺ ដូចជាសាវ័កថូម៉ាស ដែលខកខានព្រះពរ។ សូមប្រាប់ពួកគេអំពីសារៈសំខាន់នៃការស្តាប់ព្រះបន្ទូលដែលបានអធិប្បាយ ហើយថាវាគឺជាបញ្ញត្តិរបស់ព្រះសម្រាប់ការប្រែចិត្ត ការញែកជាបរិសុទ្ធ និងការកសាងព្រលឹងរបស់មនុស្ស។ សូមប្រាប់ពួកគេពីរបៀបដែលសាវ័ក ប៉ុល ដាស់តឿនយើងមិនឲ្យធ្វើ «ឥតលែងប្រជុំគ្នា ដូចជាអ្នកខ្លះធ្លាប់នោះឡើយ» (ហេព្រើរ ១០:២៥) ត្រូវឲ្យកំឡាចិត្តគ្នាវិញ ឲ្យកាន់តែខ្លាំងឡើងផង តាមដែលឃើញថា ថ្ងៃនោះជិតមកដល់ហើយ។

ខ្ញុំហៅវាថា ជាទិដ្ឋភាពដ៏ក្រៀមក្រំនៅក្នុងក្រុមជំនុំ នៅពេលដែលគ្មាននរណាម្នាក់ឡើងមកលើមកទទួលពិធីលាងព្រះអម្ចាស់។ ប៉ុន្តែខ្ញុំហៅថា ជាទិដ្ឋភាពដ៏សោកសៅមួយនៅពេលដែលមិនឃើញមានកុមារនៅក្នុងក្រុមជំនុំ លើកលែងតែកុមារដែលមកសាលាថ្ងៃអាទិត្យ ហើយមានកាតព្វកិច្ចចូលរៀន។ សូមកុំឲ្យកំហុសនេះនៅមាត់ទ្វាររបស់លោកអ្នកឡើយ។ មានក្មេងប្រុសស្រីជាច្រើន ដែលកំពុងតែនៅគ្រប់ជ្រុងព្រះវិហារ ក្រៅពីអ្នកដែលមកសាលារៀន ហើយអ្នកដែលជាឪពុកម្តាយ និងមិត្តភក្តិគួរតែអញ្ជើញ ពួកគេមកក្រុមជំនុំជាមួយលោកអ្នកដែរ។

កុំបណ្តោយឲ្យគេធំឡើងដោយមានទម្លាប់រកលេសឥតប្រយោជន៍សម្រាប់ការមិនមកចូលរួម។ ចូរប្រាប់ពួកគេឲ្យយល់ឲ្យបានច្បាស់ថា ដរាបណាពួកគេនៅក្រោមដំបូលផ្ទះរបស់លោកអ្នក វាគឺជាច្បាប់នៃផ្ទះរបស់អ្នកនោះ គឺសម្រាប់គ្រប់គ្នាដែលមាន ការគោរពដល់ព្រះដំណាក់របស់ព្រះអម្ចាស់នៅថ្ងៃរបស់ព្រះទ្រង់។ ហើយថាលោកអ្នកចាត់ទុកអ្នកដែលបំពានថ្ងៃសប្ប័ទថា ជាឃាតករដល់ព្រលឹងខ្លួនផ្ទាល់។

សូមមើលផងដែរ ប្រសិនបើអាចរៀបចំ កូនរបស់លោកអ្នកទៅក្រុមជំនុំជាមួយលោកអ្នក ហើយដាក់ពួកគេអោយអង្គុយនៅជិតលោកអ្នក នៅពេលដែលពួកគេចូលរួមថ្វាយបង្គំ។ ការទៅព្រះវិហារគឺជារឿងមួយ ប៉ុន្តែការមានអាកប្បកិរិយាល្អនៅក្រុមជំនុំគឺជារឿងមួយផ្សេងទៀត។ ហើយសូមជឿខ្ញុំថា វាមិនមានសុវត្ថិភាពណា

សម្រាប់អាកប្បកិរិយាល្អ ដូចជាការមានពួកគេនៅក្រោមក្រសែភ្នែករបស់លោកអ្នកឡើយ។

គំនិតរបស់យុវជនវ័យក្មេងងាយស្រួលក្នុងការបែរចេញ ហើយការយកចិត្តទុកដាក់របស់ពួកគេក៏បាត់បង់ ហើយគ្រប់មធ្យោបាយដែលអាចធ្វើទៅបានគួរតែត្រូវបានប្រើ ដើម្បីទប់ទល់នឹងបញ្ហានេះ។ ខ្ញុំមិនចូលចិត្តឃើញពួកគេមកក្រុមជំនុំដោយខ្លួនគេទេ។ ជាញឹកញាប់ពួកគេចូលក្នុងក្រុមមនុស្សមិនល្អ ហើយរៀនពីអំពើអាក្រក់នៅថ្ងៃរបស់ព្រះអម្ចាស់ច្រើនជាងថ្ងៃធម្មតាទាំងអស់ក្នុងសប្តាហ៍ទៅទៀត។ ខ្ញុំក៏មិនចូលចិត្តអ្វីដែលខ្ញុំឃើញ ដែលខ្ញុំហៅថា «ជ្រុងនៃយុវជន» នៅក្នុងក្រុមជំនុំដែរ។ ជាទូទៅ ពួកគេតែងតែចាប់យកទម្លាប់នៃការមិនយកចិត្តទុកដាក់ និងការមិនគោរពនៅទីនោះ ជាការដែលត្រូវចំណាយពេលរាប់ឆ្នាំ ដើម្បីឲ្យភ្លេចវិញ ប្រសិនបើពួកគេអាចភ្លេចបាន។ អ្វីដែលខ្ញុំចង់ឃើញ គឺគ្រួសារទាំងមូលអង្គុយជាមួយគ្នា ទាំងចាស់ទាំងក្មេង អង្គុយក្បែរគ្នា រួមទាំងបុរស ស្ត្រី និងកុមារា កុមារី បម្រើព្រះតាមគ្រួសាររបស់ពួកគេ។

ប៉ុន្តែ មានអ្នកខ្លះនិយាយថា វាគ្មានប្រយោជន៍ទេ ក្នុងការដាស់តឿនកុមារឲ្យចូលរួមក្នុងពិធីថ្វាយបង្គំ ពីព្រោះពួកគេមិនអាចយល់បានឡើយ។ ខ្ញុំនឹងមិនឲ្យអ្នកស្តាប់ហេតុផលបែបនេះទេ។ ខ្ញុំរកមិនឃើញមានគំនិតបែបនេះនៅក្នុងគម្ពីរសញ្ញាចាស់ទេ។ នៅពេលដែលលោកម៉ូសេ ទៅនៅចំពោះព្រះចៅផារ៉ោន (និក្ខមនំ ១០:៩) ខ្ញុំសង្កេតឃើញ

គាត់និយាយថា «យើងខ្ញុំនឹងទៅទាំងចាស់ទាំងក្មេង ទាំងកូនប្រុស កូនស្រី ដ្បិតនេះគឺជាបុណ្យព្រះយេហូវ៉ាសម្រាប់យើងខ្ញុំរាល់គ្នា»។ នៅពេលលោក យ៉ូស្វេ អានក្រឹត្យវិន័យ ខ្ញុំសង្កេតឃើញថា «គ្មានពាក្យណាដែល យ៉ូស្វេ មិនបានអាននៅមុខក្រុមជំនុំ អ៊ីស្រាអែលទាំងអស់ រួមទាំងស្ត្រី ក្មេងតូច និងមនុស្សប្លែកមុខមានវត្តមានក្នុងចំណោមពួកគេ»។ «៣ដងក្នុង១ឆ្នាំ» មានចែងនៅកណ្ឌគម្ពីរ និក្ខមនំ ៣៤:២៣ «អស់ទាំងប្រុសៗក្នុងពួកឯង គេត្រូវមកនៅចំពោះព្រះអម្ចាស់៣ដងក្នុង១ឆ្នាំ គឺមកចំពោះព្រះយេហូវ៉ាជាព្រះនៃសាសន៍អ៊ីស្រាអែល»។ ហើយនៅពេលដែលខ្ញុំងាកទៅគម្ពីរសញ្ញាថ្មី ខ្ញុំឃើញក្មេងៗដែលបានរៀបរាប់នៅទីនោះ គឺជាការចូលរួមនៅក្នុងសកម្មភាពពន្ធកិច្ចសកម្មភាពក្នុងព្រះវិហារ ដូចជានៅក្នុងសម័យសញ្ញាចាស់ផងដែរ។ នៅពេលដែលសាវ័ក ប៉ុល កំពុងចាកចេញពីពួកសិស្សនៅឯក្រុងទីរ៉ុសជាលើកចុងក្រោយ ខ្ញុំរកឃើញបាននិយាយថា (កិច្ចការ ២១:៥) «ឯពួកគេទាំងអស់ព្រមទាំងប្រពន្ធកូនបានជូនយើងខ្ញុំទៅខាងក្រៅទីក្រុងរួចយើងលុតជង្គង់អធិស្ឋាននៅមាត់ច្រាំង»។

ក្នុងវ័យកុមារភាពរបស់គាត់ សាំយូអែល ហាក់ដូចជាបានបម្រើព្រះអម្ចាស់មួយរយៈ មុនពេលដែលបានស្គាល់ព្រះពិតប្រាកដ។ «ឯសាំយូអែលមិនទាន់ស្គាល់ព្រះយេហូវ៉ានៅឡើយទេ ព្រះបន្ទូលនៃទ្រង់ក៏មិនទាន់បានសម្តែងមកឲ្យដឹងដែរ» (១សាំយូអែល ៣:៧)។ ពួកសាវ័កហាក់បីដូចជាមិនយល់នូវអ្វីទាំងអស់ដែលព្រះអម្ចាស់

នៃយើងបានមានបន្ទូលអំពីអ្វីដែលទ្រង់មានបន្ទូល «មុនដំបូងពួកសិស្សទ្រង់មិនបានយល់សេចក្តីទាំងនោះទេ តែកាលព្រះយេស៊ូវបានតម្កើងឡើងហើយ នោះគេនឹងឃើញថា មានសេចក្តីទាំងនោះចែងទុកពីទ្រង់ ហើយថា គេបានសម្រេចការទាំងនោះថ្វាយទ្រង់ដែរ» (យ៉ូហាន ១២:១៦)។

ឪពុកម្តាយទាំងឡាយ សូមសម្រាលទុក្ខរបស់លោកអ្នកដោយគំរូឧទាហរណ៍ទាំងនេះ។ កុំឲ្យធ្លាក់ទឹកចិត្ត ដោយសារតែកូនរបស់លោកអ្នកមើលមិនទាន់ឃើញអំពីតម្លៃពេញលេញនៃព្រះគុណនៅពេលឥឡូវនេះក៏ដោយ។ អ្វីដែលលោកអ្នកធ្វើបន្តគឺត្រូវតែបង្ហាត់ពួកគេឲ្យមានទម្លាប់ចូលរួមជាប្រចាំ។ កំណត់វានៅចំពោះគំនិតរបស់ពួកគេថាជាកាតព្វកិច្ចដ៏ខ្ពង់ខ្ពស់ បរិសុទ្ធ និងដ៏ឧឡារិក ហើយសូមជឿជាក់លើខ្ញុំ ថ្ងៃនោះទំនងជានឹងមកដល់ ជាពេលដែលពួកគេនឹងដឹងគុណលោកអ្នកសម្រាប់ទង្វើរបស់លោកអ្នក។

ជំពូក៨

សូមបណ្តុះបណ្តាលពួកគេជាមួយទម្លាប់នៃជំនឿ

ខ្ញុំចង់និយាយថា លោកអ្នកគួរតែបង្ហាត់គេឲ្យជឿនូវអ្វីដែលលោកអ្នកនិយាយ។ លោកអ្នកគួរតែព្យាយាមធ្វើឲ្យពួកគេមានអារម្មណ៍ជឿជាក់លើការវិនិច្ឆ័យរបស់លោកអ្នក ហើយគោរពយោបល់របស់លោកអ្នកថាប្រសើរជាងរបស់ពួកគេផ្ទាល់។ លោកអ្នកគួរទម្លាប់ឲ្យគេគិតថា ពេលណាលោកអ្នកនិយាយថាវាអាក្រក់សម្រាប់ពួកគេ នោះវាត្រូវតែអាក្រក់ ហើយពេលណាលោកអ្នកនិយាយថាវាល្អសម្រាប់ពួកគេ នោះវាក៏ត្រូវតែល្អ ។ សរុបមកគឺថា ចំណេះដឹងរបស់លោកអ្នកគឺល្អជាងរបស់ពួកគេ ហើយពួកគេអាចពឹងផ្អែកទាំងស្រុងលើពាក្យរបស់លោកអ្នក។ លោកអ្នកត្រូវបង្រៀនពួកគេឲ្យមានអារម្មណ៍ថា អ្វីដែលពួកគេមិនដឹងនៅពេលនេះ ពួកគេប្រហែលជានឹងដឹងនៅពេលក្រោយ ហើយដើម្បីឲ្យពួកគេពេញចិត្តនោះគឺជាហេតុផលនិងតម្រូវការសម្រាប់អ្វីគ្រប់យ៉ាងដែលលោកអ្នកតម្រូវឲ្យពួកគេធ្វើ។

តើអ្នកណាអាចពណ៌នាអំពីព្រះពរខាងឯព្រលឹងវិញ្ញាណនៃជំនឿដ៏ពិតប្រាកដបាន? ឬផ្ទុយទៅវិញ តើអ្នកណាអាចប្រាប់ពីទុក្ខវេទនាដែលការមិនជឿដែលបាននាំមកលើពិភពលោកនេះ? ការមិនជឿបាន

ធ្វើឲ្យ អេវ៉ា បរិភោគផ្លែឈើហាមឃាត់—នាងសង្ស័យពីសេចក្តីពិត នៃព្រះបន្ទូលរបស់ព្រះ—«នោះនឹងត្រូវស្លាប់ជាមិនខាន»។ ការមិនជឿបានធ្វើឲ្យពិភពលោកសម័យមុនបដិសេធការព្រមានរបស់លោក ណូអេ ដូច្នេះហើយត្រូវវិនាសក្នុងអំពើបាប។ ការមិនជឿបានធ្វើឲ្យពួកអ៊ីស្រាអែលនៅទីរហោស្ថាន វាជារនាំងដែលរារាំងពួកគេមិនឲ្យចូលទៅក្នុងទឹកដីសន្យា។ ការមិនជឿបានធ្វើឲ្យជនជាតិយូដាឆ្កាងព្រះអម្ចាស់នៃសិរីល្អ គឺពួកគេមិនជឿសម្តីរបស់លោក ម៉ូសេ និងពួកហោរាឡើយ ទោះបីជាមានអ្នកបានអានឲ្យពួកគេស្តាប់រាល់ថ្ងៃក៏ដោយ។ ហើយការមិនជឿ គឺជាអំពើបាបដែលគ្រប់គ្រងលើចិត្តរបស់មនុស្សរហូតមកដល់ម៉ោងនេះ គឺការមិនជឿលើការសន្យារបស់ព្រះ ការមិនជឿលើការព្រមានរបស់ព្រះ ការមិនជឿថា លទ្ធផលនៃអំពើបាបរបស់យើង គឺជាសេចក្តីស្លាប់ ការមិនជឿលើអ្វីគ្រប់យ៉ាងដែលប្រឆាំងនឹងអំនួត និងភាពលោភលន់នៃចិត្តដ៏អាក្រក់របស់យើង។ ប្រិយមិត្តអ្នកអាន លោកអ្នកបង្ហាត់កូនរបស់លោកអ្នកឲ្យមានគោលបំណងតិចតួចណាស់ ប្រសិនបើលោកអ្នកមិនបង្ហាត់ពួកគេឲ្យមានទម្លាប់នៃការរស់នៅដោយសេចក្តីជំនឿទាំងស្រុងទេនោះ។ ការជឿលើពាក្យសម្តីរបស់ឪពុកម្តាយពួកគេ មានទំនុកចិត្តថាអ្វីដែលឪពុកម្តាយរបស់ពួកគេនិយាយពិតជាត្រឹមត្រូវ។

ខ្ញុំធ្លាប់បានឮអ្នកខ្លះនិយាយថា លោកអ្នកមិនគួរទាមទារអ្វីពីកូនដែលពួកគេមិនអាចយល់បានទេ។ ដូច្នេះហើយ លោកអ្នកគួរតែ

ពន្យល់ និងផ្តល់ហេតុផលសម្រាប់អ្វីគ្រប់យ៉ាងដែលលោកអ្នកចង់ឲ្យ
ពួកគេធ្វើ។ ខ្ញុំព្រមានលោកអ្នកយ៉ាងមុឺងម៉ាត់ប្រឆាំងនឹងគំនិត
បែបនេះ។ ខ្ញុំប្រាប់លោកអ្នកឲ្យច្បាស់ថា ខ្ញុំគិតថា វាជាគោលការណ៍
មិនសមហេតុផលទេ។ គ្មានអ្វីត្រូវសង្ស័យទេ វាគឺជាការឥតទំនងក្នុង
ការបង្កើតអាថ៌កំបាំងនៃអ្វីគ្រប់យ៉ាងដែលលោកអ្នកធ្វើ ហើយមានរឿង
ជាច្រើនដែលវាជាការល្អក្នុងការពន្យល់ដល់កុមារ ដើម្បីឲ្យពួកគេអាច
យើញថា ពួកគេមានហេតុផល និងមានប្រាជ្ញា។ ប៉ុន្តែ ក្នុងការបណ្តុះ
ពួកគេឡើងជាមួយនឹងគំនិតដែលថា ពួកគេមិនត្រូវការជឿទុកចិត្តលើ
អ្វីទាំងអស់ នោះពួកគេនឹងសួរជាមួយនឹងការយល់ដឹងដ៏ទន់ខ្សោយ
និងមិនល្អឥតខ្ចោះរបស់ខ្លួនគឺ «ហេតុអ្វី» និង «បើដូច្នេះ» ។ បាន
បញ្ជាក់យ៉ាងច្បាស់ដល់ពួកគេថា នៅគ្រប់ជំហានដែលពួកគេធ្វើ
គឺនេះពិតជាកំហុសដ៏គួរឲ្យភ័យខ្លាច ហើយទំនងជាមានឥទ្ធិពល
អាក្រក់បំផុតលើគំនិតរបស់ពួកគេ។

ត្រូវមានហេតុផលជាមួយកូនរបស់លោកអ្នក បើលោកអ្នក
ពិតជាត្រូវដោះស្រាយ នៅពេលខ្លះ។ ប៉ុន្តែ កុំភ្លេចចងចាំគាត់
(ប្រសិនបើលោកអ្នកពិតជាស្រឡាញ់គាត់) ថា គាត់គ្រាន់តែជា
កូនក្មេងម្នាក់ ដែលគាត់គិតដូចជាក្មេង គាត់យល់ដូចជាកូនក្មេង។
ដូច្នេះហើយ មិនត្រូវរំពឹងថានឹងដឹងពីហេតុផលនៃអ្វីៗទាំងអស់
ក្នុងពេលតែមួយនោះទេ។

យកគំរូរបស់លោក អ៊ីសាក ដាក់នៅចំពោះមុខគាត់ នៅថ្ងៃដែល

លោក អ័ប្រាហាំ នាំគាត់ទៅថ្វាយជាយញ្ញបូជានៅលើភ្នំម៉ូរីយ៉ា (លោកុប្បត្តិ ២២)។ គាត់បានសួរឪពុកគាត់នូវសំណួរតែមួយគត់ថា «តើកូនចៀមសម្រាប់តង្វាយដុតនៅឯណា?» ហើយគាត់មិនទទួលបានចម្លើយអ្វីក្រៅពីការនេះថា «ព្រះទ្រង់នឹងផ្គត់ផ្គង់ឲ្យ»។ របៀបណា កន្លែងណា តាមរបៀបណា ឬដោយមធ្យោបាយអ្វីនោះទេ។ ការទាំងនេះមិនបានប្រាប់ដល់ អ៊ីសាក ទេ ប៉ុន្តែចម្លើយ គឺគ្រប់គ្រាន់ហើយ។ គាត់ជឿថា វានឹងល្អ ពីព្រោះឪពុកគាត់និយាយដូច្នោះ ហើយគាត់ពេញចិត្ត។

សូមប្រាប់កូនរបស់លោកអ្នកផងដែរថា យើងទាំងអស់គ្នាត្រូវតែជាអ្នករៀននៅថ្នាក់ ដំបូងរបស់យើង ហើយថាមានអក្ខរក្រម ដែលយើងត្រូវស្ទាត់ជំនាញគ្រប់បែបយ៉ាង ហើយថាសេះដែលល្អបំផុតក្នុងពិភពលោកត្រូវការពេលដើម្បីបង្ហាត់ ហើយថាថ្ងៃណាមួយនឹងមកដល់នៅពេលនោះ ពួកគេនឹងឃើញប្រាជ្ញានៃការបណ្តុះបណ្តាលរបស់លោកអ្នក។ ប៉ុន្តែ ក្នុងពេលនេះប្រសិនបើលោកអ្នកនិយាយអ្វីមួយថា «ត្រូវ» វាត្រូវតែគ្រប់គ្រាន់សម្រាប់ពួកគេហើយ។ ពួកគេត្រូវតែជឿលោកអ្នក ហើយស្តប់ចិត្ត។

ឪពុកម្តាយទាំងឡាយ ប្រសិនបើចំណុចណាមួយក្នុងការបណ្តុះបណ្តាលដែលមានសារៈសំខាន់ នោះវាគឺជាការនេះឯង។ ខ្ញុំបង្គាប់លោកអ្នកដោយក្តីស្រឡាញ់ដែលលោកអ្នកមានចំពោះកូនរបស់លោកអ្នក សូមប្រើគ្រប់មធ្យោបាយ ដើម្បីបង្ហាត់ពួកគេឲ្យ

បណ្តុះបណ្តាលកូនរបស់លោកអ្នកឲ្យមានទម្លាប់នៃការស្តាប់បង្គាប់

ទេ ជាកម្មវត្ថុដែលស័ក្តិសម ដើម្បីសម្រេចឲ្យបាន។ ខ្ញុំគិតថា គ្មានទម្លាប់ណាដែលមានឥទ្ធិពលមកលើជីវិតរបស់យើងបែបនេះនោះទេ។ ឪពុកម្តាយទាំងឡាយ ចូរតាំងចិត្តធ្វើឲ្យកូនរបស់លោកអ្នកចេះស្តាប់បង្គាប់លោកអ្នក ទោះបីជាវាអាចធ្វើឲ្យលោកអ្នកមានបញ្ហាច្រើនក៏ដោយ ហើយធ្វើឲ្យពួកគេស្រក់ទឹកភ្នែកជាច្រើនក៏ដោយ! កុំឲ្យមានការស្តីរដេញដោល ការវែកញែក ការប្រកែកគ្នា ការពន្យារពេល ហើយឆ្លើយតបវិញឡើយ។ ពេលលោកអ្នកបញ្ជាក់ឲ្យគេឃើញច្បាស់ថា លោកអ្នកនឹងធ្វើវាបាន។

ការស្តាប់បង្គាប់ គឺជាការពិតតែមួយគត់ ដែលបង្ហាញអំពីជំនឿដែលអាចមើលឃើញ ជំនឿដែលមានការប្រព្រឹត្ត និងជំនឿដែលមានរូបរាង។ វាគឺជាការសាកល្បងនៃភាពជាសិស្សពិតប្រាកដក្នុងចំណោមរាស្ត្ររបស់ព្រះអម្ចាស់។ «បើអ្នករាល់គ្នាធ្វើតាមសេចក្តីដែលខ្ញុំបង្គាប់នោះអ្នករាល់គ្នាជាពួកសំឡាញ់ខ្ញុំហើយ» (យ៉ូហាន ១៥:១៤)។ វាគួរតែជាសញ្ញាសម្គាល់របស់កូន ដែលបានបណ្តុះបណ្តាលយ៉ាងល្អថា ពួកគេរីករាយនឹងធ្វើអ្វីដែលឪពុកម្តាយបង្គាប់ពួកគេ។ ពិតប្រាកដ

ណាស់ តើកិត្តិយសដែលបញ្ញត្តិទីប្រាំបានចែងនៅទីណា ប្រសិនបើកូនៗមិនទទួលបានការស្តាប់បង្គាប់ ដោយស្ម័គ្រចិត្ត និងភ្លាមៗទេនោះ?

ការស្តាប់បង្គាប់គឺមានមានបទគម្ពីរគាំទ្រទាំងអស់។ វាគឺបានលើកឡើងក្នុងគ្រួសារ របស់លោក អ័ប្រាហាំ មិនត្រឹមតែគាត់នឹងបង្ហាត់បង្រៀនគ្រួសាររបស់គាត់ប៉ុណ្ណោះទេ ប៉ុន្តែ «គាត់នឹងបង្គាប់ដល់កូនចៅ និងពួកផ្ទះគាត់តរៀងទៅ»(លោកុប្បត្តិ ១៨:១៩)។ ហើយត្រូវបានគេនិយាយអំពីព្រះអម្ចាស់យេស៊ូវគ្រីស្ទផ្ទាល់ថា «កាលទ្រង់នៅក្មេង ទ្រង់ចុះចូលនឹង ម៉ារា និង យ៉ូសែប» (លូកា ២:៥១)។ សូមសង្កេតមើលថា តើ យ៉ូសែប បានគោរពតាមបញ្ជារបស់ យ៉ាកុប ជាឪពុករបស់គាត់យ៉ាងដូចម្តេច (លោកុប្បត្តិ ៣៧:១៣)។ សូមមើលពីរបៀបដែលហោរា អេសាយ និយាយអំពីវាថា ជាអំពើអាក្រក់ នៅពេលដែល «ពួកក្មេងៗនឹងប្រព្រឹត្តព្រហើនចំពោះចាស់ព្រឹទ្ធាចារ្យ» (អេសាយ ៣:៥)។ សូមគូសចំណាំអំពីរបៀបដែលសាវ័ក ប៉ុល កំណត់ការមិនស្តាប់បង្គាប់ឪពុកម្តាយថា ជាសញ្ញាអាក្រក់មួយនៃថ្ងៃចុងក្រោយបង្អស់ (២ធីម៉ូថេ ៣:២)។ សូមគូសចំណាំពីរបៀបដែលគាត់ទាមទារចំពោះបុគ្គលដែលតែងតាំងអ្នកដឹកនាំគ្រីស្ទបរិស័ទ «អ្នកត្រួតត្រាត្រូវត្រួតត្រាផ្ទះរបស់ខ្លួន ដោយស្រួលបួល ទាំងឲ្យកូនចៅស្តាប់បង្គាប់ដោយនឹងធឹង»។ ហើយជាថ្មីទៀតថា៖ «ត្រូវឲ្យអ្នកជំនួយត្រួតត្រាកូនចៅ និងផ្ទះខ្លួន ដោយស្រួលបួល» (១ធីម៉ូថេ ៣:៤,១២)។ ជាថ្មី

ម្តងទៀត អ្នកចាស់ទុំត្រូវតែជាមនុស្សម្នាក់ដែល «មានកូនចៅជឿដែរ ឥតមានអ្នកណាចោទប្រកាន់ ថាជាមនុស្សខូចអាក្រក់ ឬរឹងចចេសអ្វីឡើយ» (ទីតុស ១:៦)។

ឪពុកម្តាយទាំងឡាយ តើលោកអ្នកចង់ឃើញកូនៗ សប្បាយចិត្តឬទេ? ដូច្នេះ សូមយកចិត្តទុកដាក់ថា លោកអ្នកនឹងបង្ហាត់ពួកគេឲ្យស្តាប់តាមពេលលោកអ្នកនិយាយទៅកាន់គេ ត្រូវធ្វើដូចដែលគេត្រូវបានបង្គាប់។ សូមជឿខ្ញុំ យើងមិនត្រូវបានបង្កើតឡើងសម្រាប់ឯករាជ្យភាពទាំងស្រុងទេ។ យើងមិនសមនឹងវាទេ។ សូម្បីតែអ្នកដែលមានសេរីភាពរបស់ព្រះគ្រីស្ទក៏មានន័យសម្រាប់ពាក់ដែរ ពួកគេ «បម្រើព្រះគ្រីស្ទ» (កូឡុស ៣:២៤)។ កុមារមិនអាចរៀនឆាប់ពេកទេថា នេះគឺជាពិភពលោក ដែលយើងទាំងអស់គ្នាមិនមានបំណងគ្រប់គ្រង ហើយថាយើងមិននៅកន្លែងត្រឹមត្រូវរបស់យើងនេះទេ រហូតដល់យើងដឹងពីរបៀបស្តាប់បង្គាប់ដែលប្រសើរជាង។ បង្រៀនពួកគេឲ្យស្តាប់បង្គាប់ទាំងនៅក្មេង បើមិនដូច្នេះទេ ពួកគេនឹងខឹងនឹងព្រះពេញមួយជីវិតរបស់ពួកគេ ហើយដាក់បន្ទុកខ្លួនគេដោយគំនិតឥតប្រយោជន៍នៃភាពឯករាជ្យ ក្រៅពីការគ្រប់គ្រងរបស់ទ្រង់។

ប្រិយមិត្តអ្នកអាន យើងត្រូវការជំនួយនេះខ្លាំងណាស់។ លោកអ្នកនឹងឃើញមនុស្សជាច្រើននៅសម័យនេះដែលបានអនុញ្ញាតឲ្យកូនរបស់ពួកគេជ្រើសរើសដោយខ្លួនឯង និងគិតសម្រាប់ខ្លួនឯង មុន

ពេលដែលពួកគេគិតគូរ ហើយថែមទាំងរកលេស ចំពោះការមិន
ស្តាប់បង្គាប់របស់ពួកគេ ធ្វើដូចជារឿងដែលមិនគួរត្រូវបន្ទោស។ នៅ
ចំពោះភ្នែករបស់ខ្ញុំ ពេលដែលឃើញ ឪពុកម្តាយតែងតែយល់ស្រប
ហើយកូនតែងតែមានផ្លូវផ្ទាល់ខ្លួន គឺជាការមើលឃើញដ៏ឈឺចាប់
បំផុត ឈឺចាប់ដោយសារខ្ញុំឃើញការចាត់តាំងរបស់ព្រះ ចំពោះអ្វី
ៗបានបញ្ចាស ហើយផ្លាស់ប្តូរ ឈឺចាប់ព្រោះខ្ញុំមានអារម្មណ៍ថា
ប្រាកដណាស់ថាលទ្ធផលចុងក្រោយនៃចរិតលក្ខណៈរបស់កុមារ
នឹងបញ្ចប់ត្រឹម ឆន្ទៈខ្លួនឯង(ធ្វើតាមចិត្តខ្លួន) អំនួត និងគិតតែពី
ខ្លួនឯង។ លោកអ្នកមិនត្រូវឆ្ងល់ទេថា ហេតុអ្វីបានជាមនុស្សបដិសេធ
មិនព្រមស្តាប់បង្គាប់ព្រះវរបិតារបស់ពួកគេដែលគង់នៅស្ថានសួគ៌នោះ
ប្រសិនបើលោកអ្នកអនុញ្ញាតឲ្យពួកគេ មិនស្តាប់បង្គាប់ឪពុកម្តាយ
របស់ពួកគេ ដែលរស់នៅលើផែនដី នោះគេក៏មិនអាចស្តាប់បង្គាប់
ព្រះដែលនៅស្ថានសួគ៌បានដែរ។ ឪពុកម្តាយទាំងឡាយអើយ បើ
លោកអ្នកស្រឡាញ់កូនរបស់ខ្លួន នោះសូមឲ្យការស្តាប់បង្គាប់ជា
បាវចនា និងជាពាក្យចងចាំជានិច្ចនៅចំពោះមុខពួកគេ។

ជំពូក១០

សូមបណ្តុះបណ្តាលពួកគេជាមួយទម្លាប់នៃការនិយាយការពិត

ការនិយាយអំពីការពិតនៅក្នុងពិភពលោកយើងនៅក្នុងសម័យនេះគឺមានតិចជាងការឃើញនៅសម័យ មុន ដែលយើងត្រូវពិចារណាមើល។ ការនិយាយការពិតទាំងស្រុង ហើយគ្មានអ្វីក្រៅពីការពិត គឺជាច្បាប់មាស ដែលមនុស្សជាច្រើនគួរតែចងចាំទុកក្នុងចិត្ត។ ការកុហក និងការនិយាយដើម គឺជាអំពើបាបចាស់។ អារក្សគឺជាឪពុកនៃការកុហក វាបានបញ្ឆោតនាង អេវ៉ា ដោយការកុហកយ៉ាងក្លាហាន ហើយចាប់តាំងពីការធ្លាក់ចូលក្នុងអំពើបាប វាគឺជាអំពើបាបដែលកូនចៅរបស់ នាង អេវ៉ា ទាំងអស់ត្រូវតែប្រុងប្រយ័ត្ន។

បើគិតអំពីភាពមិនពិត និងការបោកប្រាស់នៅលើពិភពលោកនេះ តើមានច្រើនប៉ុនណាទៅ? ហួសចិត្តប៉ុណ្ណា? តើមានការបន្ថែមច្រើនប៉ុណ្ណាទៅជារឿងសាមញ្ញ! តើមានអ្វីខ្លះត្រូវបានទុកចោល បើមិនបម្រើដល់ការចាប់អារម្មណ៍របស់អ្នកនិយាយ ដើម្បីប្រាប់គេ! តើមានមនុស្សប៉ុន្មាននាក់ដែលយើងអាចនិយាយបានថា ពួកយើងជឿជាក់លើពាក្យរបស់ពួកគេដោយមិនស្ទាក់ស្ទើរ! ពិតប្រាកដណាស់

ជនជាតិពើស៊ីពីសម័យបុរាណមានប្រាជ្ញាក្នុងជំនាន់របស់ពួកគេ វាជាចំណុចឈានមុខគេក្នុងការអប់រំកូនចៅរបស់ពួកគេ ដើម្បីឲ្យពួកគេរៀននិយាយការពិត។ ការកុហក គឺជាភស្តុតាងដ៏អាក្រក់ដែលវាជាអំពើបាបធម្មជាតិរបស់មនុស្ស។

មិត្តអ្នកអាន ខ្ញុំចង់ឲ្យអ្នកកត់សម្គាល់ថា តើញឹកញាប់ប៉ុណ្ណាដែលព្រះជាម្ចាស់បានមានបន្ទូលនៅក្នុងគម្ពីរសញ្ញាចាស់ថា អញជាព្រះនៃសេចក្តីពិត? សេចក្តីពិតហាក់ដូចជាត្រូវបានកំណត់ជាពិសេសនៅចំពោះមុខយើងជាលក្ខណៈពិសេសនាំមុខគេនៅក្នុងចរិតលក្ខណៈរបស់ទ្រង់ដែលយើងត្រូវធ្វើ។ ទ្រង់មិនដែលងាកចេញពីបន្ទាត់ត្រង់ទេ។ ទ្រង់ស្អប់ការកុហក និងការលាក់ពុត។ សូមព្យាយាមរក្សាវាជាបន្តបន្ទាប់នៅចំពោះមុខកូនរបស់លោកអ្នក។ ចូរសង្កត់ធ្ងន់លើពួកគេគ្រប់ពេលវេលាថា អ្វីដែលតិចជាងការពិតនោះ គឺជាការកុហក។ ការគេចវាស ការរកលេស និងការបំផ្លើស សុទ្ធតែជាពាក់កណ្តាលឆ្ពោះទៅរកអ្វីដែលមិនពិត ហើយគួរតែជៀសវាង។ សូមលើកទឹកចិត្តពួកគេក្នុងកាលៈទេសៈណាក៏ដោយឲ្យនិយាយដោយត្រង់ៗ ហើយទោះជាពួកគេត្រូវលះបង់អ្វីក៏ដោយ ត្រូវនិយាយការពិត។

ខ្ញុំលើកសារៈសំខាន់នៃប្រធានបទនេះមកនិយាយ មិនមែនគ្រាន់តែដើម្បីជាប្រយោជន៍ដល់ចរិតលក្ខណៈរបស់កូនលោកអ្នកនៅក្នុងពិភពលោកនោះទេ ទោះបីខ្ញុំអាចនិយាយនៅលើបញ្ហានេះច្រើនយ៉ាងណាក៏ដោយ ខ្ញុំសូមជំរុញវាសម្រាប់ការកម្សាន្តចិត្ត និងជាជំនួយដល់

លោកអ្នកផ្ទាល់ក្នុងគ្រប់ការដោះស្រាយរបស់អ្នកជាមួយពួកគេ។ លោកអ្នកនឹងរកឃើញថា វាជាជំនួយដ៏អស្ចារ្យក្នុងការអាចជឿទុកចិត្ត ពាក្យរបស់ពួកគេជានិច្ច។ វានឹងទៅលើសពីនេះ ដើម្បីការពារទម្លាប់នៃការលាក់កំបាំងនោះ ដែលពេលខ្លះមានភាពមិនសប្បាយចិត្ត ចំពោះកុមារ។ ភាពបើកចំហ និងភាពស្មោះត្រង់ពឹងផ្អែកច្រើនទៅលើការប្រព្រឹត្តរបស់ឪពុកម្តាយចំពោះបញ្ហានេះតាំងពីពេលដែលពួកគេនៅជាទារកនៅឡើយមកម្ល៉េះ។

ជំពូក១១

សូមបណ្តុះបណ្តាលពួកគេឲ្យមានទម្លាប់នៃការតែងតែមិនខ្ជះខ្ជាយពេលវេលា

ភាពខ្ជិលច្រអូស គឺជាមិត្តល្អបំផុតរបស់អារក្ស! វាជាវិធីប្រាកដប្រជាបំផុតក្នុងការផ្តល់ឱកាសឲ្យវាធ្វើបាបយើង។ ចិត្តដែលទំនេរប្រៀបដូចជាទ្វារចំហ ហើយប្រសិនបើសាតាំងមិនចូលក្នុងដោយខ្លួនវាទេ ប្រាកដណាស់ថា វានឹងបោះអ្វីមួយ ដើម្បីបំផុសឡើងនូវគំនិតអាក្រក់ក្នុងព្រលឹងយើង។

គ្មានអ្វីដែលត្រូវបានបង្កើតឡើងមក ដើម្បីឲ្យនៅទំនេរឡើយ។ សកម្មភាព និងការងារ គឺជាផ្នែកដែលបានកំណត់លក្ខណៈនៃគ្រប់ស្នាព្រះហស្តរបស់ព្រះអម្ចាស់។ ទេវតានៅស្ថានសួគ៌ធ្វើការ ។ ពួកគេគឺជាអ្នកបម្រើរបស់ព្រះអម្ចាស់ ដែលធ្វើតាមព្រះហឫទ័យរបស់ទ្រង់។ លោក អ័ដាម នៅសួនច្បារមានការងារធ្វើ គាត់ត្រូវបានតែងតាំងឲ្យគ្រប់គ្រងសួនច្បារអេដែន ហើយថែរក្សាវាទុក។ ពួកបរិសុទ្ធដែលបានប្រោសលោះដោយសិរីរុងរឿងនឹងមានការងារ «ពួកគេច្រៀងសរសើរ និងថ្វាយសិរីល្អដល់ទ្រង់ដែលបានលោះពួកគេទាំងថ្ងៃទាំងយប់ឥតឈប់ឈរ» ។ ហើយមនុស្សទន់ខ្សោយ ជាមនុស្សមានបាបត្រូវតែមានអ្វីដែលត្រូវធ្វើ បើមិនដូច្នេះទេ ព្រលឹងរបស់គាត់នឹងធ្លាក់ទៅក្នុង

ស្ថានភាពមិនល្អយ៉ាងឆាប់រហ័ស។ យើងត្រូវតែបំពេញគំនិតរបស់យើង ហើយដៃរបស់យើងត្រូវតែកាន់ដោយអ្វីមួយ បើមិនដូច្នេះទេ ការស្រមើស្រម៉ៃរបស់យើងនឹងរលាយសាបសូន្យ និងបង្កើតភាពអាក្រក់យ៉ាងឆាប់ៗរហ័ស។

ហើយអ្វីដែលពិតអំពីយើងគឺពិតសម្រាប់កូនរបស់យើងផងដែរ។ ជនជាតិយូដាបានគិតថា ភាពខ្ជិលច្រអូសគឺជាអំពើបាបវិជ្ជមាន—វាជាច្បាប់របស់ពួកគេដែលមនុស្សគ្រប់រូបគួរតែនាំកូនប្រុសរបស់ពួកគេទៅរកការធ្វើជំនួញដែលមានប្រយោជន៍—ហើយពួកគេនិយាយត្រូវ។ ពួកគេស្គាល់ចិត្តមនុស្សល្អជាងយើងខ្លះដែលបង្ហាញទៅទៀត។

ភាពខ្ជិលច្រអូសបានធ្វើឲ្យអ្នកក្រុងសូដុំមប្រែជាខូច និងអាក្រក់។ «មើលឯអំពើទុច្ចរិតរបស់អ្នកក្រុងសូដុំមជាប្អូនស្រីឯង គឺមានសេចក្តីអំនួត មានអាហារបរិភោគឆ្អែត ហើយនៅក៏ដោយឥតកង្វល់» (អេសេគាល ១៦:៤៩)។ ភាពខ្ជិលច្រអូសមានជាប់ទាក់ទងនឹងអំពើបាបដ៏អាក្រក់របស់ស្តេច ដាវីឌ ជាមួយប្រពន្ធរបស់លោក អ៊ូរី ខ្ញុំឃើញនៅក្នុងកណ្ឌគម្ពីរ២សាំយ៊ូអែលជំពូក១១៖ លោក យ៉ូអាប់ បានចេញទៅច្បាំងនឹងពួក អាំម៉ូន «ប៉ុន្តែ ព្រះបាទដាវីឌទ្រង់គង់នៅក្រុងយេរូសាឡឹមវិញ»។ តើវាមិនមែនជាការទំនេរទេឬ? ហើយបន្ទាប់មកគឺថាទ្រង់បានឃើញនាង បាតសេបា ហើយជំហានបន្ទាប់ដែលយើងបានអាន គឺការធ្លាក់ចុះយ៉ាងខ្លាំង និងដ៏អាក្រក់របស់គាត់។

ពិតមែនហើយ ខ្ញុំជឿថា ភាពខ្ជិលច្រអូសបាននាំទៅរកអំពើបាប

ច្រើនជាងទម្លាប់ណាស្មើរតែទាំងអស់ ដែលមិនបានលើកឈ្មោះមកនិយាយទៅទៀត! ខ្ញុំគិតថា វាជាម្តាយនៃកិច្ចការ ជាច្រើនខាងសាច់ឈាម គឺជាម្តាយនៃអំពើផិតក្បត់ ការសហាយស្មន់ ប្រមឹក និងអំពើឯងងឹតងងុលជាច្រើនទៀត ដែលខ្ញុំគ្មានពេលរៀបរាប់ឈ្មោះអស់។ សូមឲ្យមនសិការរបស់លោកអ្នកខ្លួនឯងនិយាយចុះ ក្រែងខ្ញុំមិននិយាយការពិត។លោកអ្នកនៅទំនេរ ហើយក្លាមៗនោះអារក្សបានគោះទ្វារចូលមក។

ហើយខ្ញុំពិតជាមិនឆ្ងល់ទេថា អ្វីៗទាំងអស់នៅក្នុងពិភពលោកជុំវិញយើងហាក់ដូចជាបង្រៀនមេរៀនដូចគ្នា។ ទឹកដែលនៅទ្រឹងតែងតែកខ្វក់ និងមិនបរិសុទ្ធ អូរដែលមានលំហូរទឹកហូរតែតែងថ្លា។ ប្រសិនបើលោកអ្នកមានម៉ាស៊ីនចំហុយ លោកអ្នកត្រូវតែដំណើរការវា បើមិនដូច្នេះទេ វានឹងខូចសណ្តាប់ធ្នាប់។ ប្រសិនបើលោកអ្នកមានសេះ លោកអ្នកត្រូវតែឲ្យវាធ្វើលំហាត់ប្រាណ វានឹងមិនល្អឡើយ បើមិនបង្ហាត់ទៀងទាត់ទេនោះ។ បើលោកអ្នកចង់មានសុខភាពរាងកាយល្អដោយខ្លួនឯង លោកអ្នកត្រូវធ្វើលំហាត់ប្រាណ។ ប្រសិនបើលោកអ្នកតែងតែអង្គុយស្ងៀម រាងកាយរបស់លោកអ្នកប្រាកដជានឹងតួញត្អែរ។ ហើយវាក៏ដូចគ្នាដែរជាមួយនឹងព្រលឹងដែរ។ គំនិតដែលមានចលនាសកម្ម គឺជាសញ្ញាពិបាកមួយសម្រាប់អារក្សបាញ់។ សូមព្យាយាមបំពេញការងារដែលមានប្រយោជន៍ជានិច្ច ដូច្នេះសត្រូវរបស់លោកអ្នកនឹងពិបាករកកន្លែងសម្រាប់សាបព្រោះ។

មិត្តអ្នកអាន ខ្ញុំសុំឲ្យលោកអ្នកកំណត់រឿងទាំងនេះនៅចំពោះគំនិតរបស់កូនលោកអ្នក។ បង្រៀនពួកគេពីតម្លៃនៃពេលវេលា ហើយព្យាយាមធ្វើឲ្យពួកគេរៀនទម្លាប់នៃការប្រើប្រាស់វាឲ្យបានល្អ។ វាធ្វើឲ្យខ្ញុំឈឺចាប់ពេលឃើញក្មេងៗនៅទំនេរពីអ្វីដែលពួកគេមាននៅក្នុងដៃ ទោះបីវាជាអ្វីក៏ដោយ។ ខ្ញុំចូលចិត្តឃើញពួកគេសកម្ម និងឧស្សាហ៍ព្យាយាម ហើយដាក់ចិត្តទាំងស្រុងលើអ្វីដែលពួកគេធ្វើ។ ដាក់ចិត្តទាំងស្រុងទៅលើមេរៀន នៅពេលដែលពួកគេត្រូវរៀន ដាក់ចិត្តរបស់ពួកគេទាំងស្រុង សូម្បីតែលើការកម្សាន្តរបស់ពួកគេ នៅពេលដែលពួកគេទៅលេង។

ប៉ុន្តែ ប្រសិនបើលោកអ្នកស្រឡាញ់ពួកគេពិត សូមឲ្យភាពខ្ជិលច្រអូសត្រូវបានរាប់ថា ជាអំពើបាបនៅក្នុងគ្រួសារលោកអ្នក។

ជំពូក១២

សូមបណ្តុះបណ្តាលពួកគេជាមួយការភ័យខ្លាច នៃការបណ្តោយខ្លួនហួសហេតុដោយឥតឈប់ឈរ

ទេ គឺជាចំណុចមួយចាំបាច់មួយ ដែលលោកអ្នកត្រូវការបំផុតក្នុងការការពារខ្លួន។ វាជាធម្មជាតិដែលមានចិត្តទន់ភ្លន់ និងស្រឡាញ់ចំពោះសាច់ឈាមរបស់លោកអ្នកផ្ទាល់ ហើយវាលើសពីភាពទន់ភ្លន់ និងក្តីស្រឡាញ់ដែលលោកអ្នកត្រូវខ្លាច។ សូមប្រយ័ត្នថា វាមិនធ្វើឲ្យលោកអ្នកខ្វាក់ភ្នែកចំពោះកំហុសរបស់កូនលោកអ្នក ហើយថ្លង់ចំពោះដំបូន្មានទាំងអស់អំពីពួកគេឡើយ។ សូមប្រយ័ត្នក្រែងវាធ្វើឲ្យលោកអ្នកមើលរំលងការប្រព្រឹត្តអាក្រក់ ជាជាងមានការឈឺចាប់ដោយសារការដាក់ទណ្ឌកម្ម និងការកែតម្រូវ។ ខ្ញុំដឹងច្បាស់ថា ការដាក់ទណ្ឌកម្ម និងការកែតម្រូវ គឺជារឿងមិនចុះសម្រុងគ្នា។ គ្មានអ្វីដែលមិនសប្បាយចិត្តជាងការផ្តល់ការឈឺចាប់ដល់អ្នកដែលយើងស្រឡាញ់ ហើយធ្វើឲ្យគេស្រក់ទឹកភ្នែកឡើយ។ ប៉ុន្តែ ដរាបណាចិត្តនៅតែជាចិត្ត នោះវាជាការឥតប្រយោជន៍ក្នុងការសន្មតថា វាជាច្បាប់ទូទៅដែលកុមារអាចត្រូវបានចិញ្ចឹមដោយមិនមានការកែតម្រូវ។

ការធ្វើឲ្យខូច គឺជាពាក្យដែលបង្ហាញអារម្មណ៍ខ្លាំង ហើយពោរពេញទៅដោយអត្ថន័យគួរឲ្យសោកស្តាយ។ ឥឡូវនេះ វាគឺជាវិធីលឿន

បំផុតក្នុងការបង្ហូចកុមារ គឺការអនុញ្ញាតឲ្យពួកគេធ្វើតាមផ្លូវរបស់ខ្លួនគេ ដើម្បីអនុញ្ញាតឲ្យពួកគេធ្វើខុស និងមិនដាក់ទណ្ឌកម្មពួកគេសម្រាប់កំហុសនោះ។ សូមជឿខ្ញុំទៅ លោកអ្នកមិនត្រូវធ្វើបែបនេះឡើយ ទោះបីឈឺចាប់យ៉ាងណាក៏ដោយ លើកលែងតែលោកអ្នកចង់បំផ្លាញព្រលឹងកូនរបស់លោកអ្នក។

លោកអ្នកមិនអាចនិយាយថា បទគម្ពីរមិនបាននិយាយច្បាស់អំពីរឿងនេះទេ «អ្នកណាដែលមិនសូវប្រើរំពាត់ នោះឈ្មោះថា ស្អប់កូន តែអ្នកណាដែលស្រឡាញ់កូនវិញ នោះឧស្សាហ៍វាយផ្ចាលវា» (សុភាសិត ១៣:២៤)។ «ចូរវាយផ្ចាលកូន ក្នុងកាលដែលនៅមានសង្ឃឹមឲ្យវារាងចាលនៅឡើយ មិនគួរនឹងលើកលែងចោលវាឲ្យត្រូវវិនាសទេ» (សុភាសិត ១៩:១៨)។ «សេចក្ដីចម្កួត រមែងនៅជាប់ក្នុងចិត្តរបស់កូនក្មេង ប៉ុន្តែរំពាត់វាយផ្ចាលនឹងបណ្តេញសេចក្ដីនោះឲ្យបាត់ចេញបាន» (សុភាសិត ២២:១៥)។ «កុំឲ្យខាននឹងវាយប្រដៅកូនឡើយ ដ្បិតបើវាយនឹងរំពាត់គង់តែមិនស្លាប់ដែរ គឺឯងនឹងគ្រាន់តែវាយដោយរំពាត់ប៉ុណ្ណោះ ហើយយ៉ាងនោះនឹងជួយព្រលឹងវាឲ្យរួចពីស្ថានឃុំព្រលឹងមនុស្សស្លាប់» (សុភាសិត ២៣:១៣, ១៤)។ «រំពាត់ និងសេចក្ដីប្រៀនប្រដៅ រមែងឲ្យកើតមានប្រាជ្ញា តែកូនណាដែលបណ្តោយឲ្យប្រព្រឹត្តតាមអំពើចិត្ត នោះតែងធ្វើឲ្យម្តាយមានសេចក្ដីខ្មាសវិញ... ចូរស្តីប្រដៅកូនឯងចុះ ទោះវានឹងឲ្យឯងបានសម្រាកចិត្តអើ វានឹងឲ្យឯងមានចិត្តរីករាយផង» (សុភាសិត ២៩:១៥, ១៧)។

តើអត្ថបទទាំងនេះខ្លាំង និងបង្ខំប៉ុណ្ណា! ការពិតគួរឲ្យសោកសង្រេងណាស់ ដែលនៅក្នុងគ្រួសារគ្រីស្ទបរិស័ទជាច្រើនហាក់ដូចជាពួកគេស្ទើរតែមិនស្គាល់! កូនៗរបស់ពួកគេត្រូវការការស្តីបន្ទោស ប៉ុន្តែវាស្ទើរតែមិនត្រូវបានធ្វើឡើងសោះ ពួកគេត្រូវការការកែតម្រូវ ប៉ុន្តែវាស្ទើរតែមិនដែលធ្វើឡើងឡើយ។ ប៉ុន្តែ សៀវភៅសុភាសិតនេះវាមិនហួសសម័យ ហើយមិនមែនមិនសមរម្យសម្រាប់គ្រីស្ទបរិស័ទនោះទេ។ វាត្រូវបានផ្តល់ឲ្យដោយការបំផុសគំនិតរបស់ព្រះ ហើយមានប្រយោជន៍។ វាត្រូវបានផ្តល់ឲ្យសម្រាប់ការរៀនសូត្ររបស់យើង សូម្បីតែជាសំបុត្រដល់អ្នកជឿនៅក្រុងរ៉ូម និងអេភេសូរផង។ ពិតប្រាកដ អ្នកជឿដែលចិញ្ចឹមកូនដោយមិនបានយកចិត្តទុកដាក់នឹងឱវាទរបស់ខ្លួន គឺធ្វើឲ្យខ្លួនឯងមានប្រាជ្ញាលើសពីអ្វីដែលមានចែងទុក នោះហើយជាកំហុសយ៉ាងធំ។

ឪពុកម្តាយរាល់គ្នាអើយ ខ្ញុំប្រាប់អ្នករាល់គ្នាយ៉ាងច្បាស់ថា ប្រសិនបើលោកអ្នកមិនដាក់វិន័យកូនក្នុងពេលដែលកូនមានកំហុសទេ នោះលោកអ្នកកំពុងធ្វើខុសយ៉ាងធ្ងន់ធ្ងរហើយ។ ខ្ញុំសូមដាស់តឿនអ្នករាល់គ្នាថា នេះជាថ្មដែលប្រជារាស្ត្រនៃព្រះគ្រប់សម័យកាលតែងតែមានការខកខាន។ ខ្ញុំសូមបញ្ចុះបញ្ចូលលោកអ្នក ដោយស្មោះអស់ពីចិត្តឲ្យមានប្រាជ្ញាទាន់ពេលវេលា ហើយរក្សាវាឲ្យបានច្បាស់លាស់។ សូមមើលវានៅក្នុងករណីរបស់ អេលី។ កូនប្រុសរបស់គាត់ ហូបនី និង ភីនេហាស «បានធ្វើខ្លួនជាមនុស្សអាក្រក់

ហើយគាត់មិនបានឃាត់ពួកគេឡើយ»។ គាត់បានត្រឹមតែស្តីបន្ទោសគេមិនលើសពីការស្តីបន្ទោសដ៏ស្លូតបូត ហើយមិនក្តៅក្រហាយឡើយ នៅពេលដែលគាត់គួរតែបន្ទោសគេយ៉ាងខ្លាំង។ និយាយឲ្យខ្លីទៅ គឺគាត់បានលើកតម្កើងកូនប្រុសរបស់គាត់លើសជាងព្រះ។ ហើយអ្វីទៅជាទីបញ្ចប់នៃរឿងនេះ? គាត់រស់នៅដើម្បីឮពីការស្លាប់របស់កូនប្រុសទាំងពីររបស់គាត់នៅក្នុងសមរភូមិ ហើយសក់ស្កូវរបស់គាត់ត្រូវបានទម្លាក់ទៅក្នុងផ្នូរដោយទុក្ខព្រួយ (១សាំយូអែល ២:២២-២៥, ៣:១៣)។

សូមមើលផងដែរពីករណីរបស់ស្តេច ដាវីឌ។ តើនរណាអាចអានប្រវត្តិរបស់កូនៗគាត់ដោយមិនឈឺចាប់ និងអំពើបាបរបស់ពួកគេ? ការរួមរ័ករបស់លោក អាំណូន ការសម្លាប់ និងការបះបោរដោយអំនួតរបស់លោក អាប់សាឡុម មហិច្ឆតារបស់លោក អ័ដូនីយ៉ា ទាំងនេះគឺពិតជារបួសដ៏ធ្ងន់ធ្ងរសម្រាប់បុរសដែលមានចិត្តត្រូវនឹងព្រះហឫទ័យព្រះ ទទួលបានពីផ្ទះរបស់គាត់ផ្ទាល់។ ប៉ុន្តែ តើគាត់គ្មានកំហុសទេឬ? ខ្ញុំឆ្លើយថា គ្មានការសង្ស័យទេ គឺមាន។ ខ្ញុំរកឃើញតម្រុយរបស់វាទាំងអស់នៅក្នុងដំណើររឿងរបស់លោក អ័ដូនីយ៉ា ក្នុងពង្សាវតារខ្សែទី១ «ព្រះបិតារបស់ទ្រង់មិនដែលធ្វើឲ្យទាស់ចិត្តម្តង ដោយពាក្យថា ហេតុអ្វីបានជាធ្វើដូច្នេះនោះឡើយ» នោះគឺជាមូលដ្ឋានគ្រឹះនៃអំពើអាក្រក់ទាំងអស់។ ស្តេច ដាវីឌ ជាឪពុកដែល បណ្តោយកូនហួសហេតុពេក ជាឪពុកដែលទុកឲ្យកូនធ្វើតាមផ្លូវរៀងៗខ្លួន ហើយ

គាត់ប្រមូលផលតាមអ្វីដែលគាត់បានសាបព្រោះ!

ឪពុកម្តាយទាំងឡាយអើយ ខ្ញុំសូមអង្វរលោកអ្នកសម្រាប់ជាប្រយោជន៍ដល់កូនរបស់លោកអ្នក សូមប្រយ័ត្នចំពោះភាពបណ្តែតបណ្តោយហួស។ ខ្ញុំសូមអំពាវនាវឲ្យលោកអ្នកចងចាំថា វាជាកាតព្វកិច្ចដំបូងរបស់លោកអ្នក ក្នុងការគិតអំពីផលប្រយោជន៍ពិតប្រាកដរបស់កូនៗ មិនមែនដោយទំនើងចិត្តនិងការចូលចិត្តរបស់ពួកគេនោះទេ គឺដើម្បីបណ្តុះបណ្តាលពួកគេ មិនមែនដើម្បីលេងសើចទេ តែដើម្បីប្រយោជន៍ដល់ពួកគេ មិនមែនគ្រាន់តែដើម្បីផ្គាប់ចិត្តពួកគេនោះទេ។

លោកអ្នកមិនត្រូវផ្តល់ឱកាសទៅគ្រប់បំណងប្រាថ្នា និងភាពភ្លើតភ្លើនៃចិត្តរបស់កូនលោកអ្នកឡើយ ទោះជាយ៉ាងណាក៏ដោយ ក៏លោកអ្នកអាចនឹងស្រឡាញ់គេយ៉ាងខ្លាំងបាន។ លោកអ្នកមិនត្រូវឲ្យគាត់គិតថា ឆន្ទៈរបស់គាត់ជាអ្វីៗទាំងអស់ ដែលថាគាត់គ្រាន់តែចង់បានរបស់មួយ ហើយវានឹងបានសម្រេចនោះឡើយ។ កុំឡើយ ខ្ញុំសូមអង្វរលោកអ្នក សូមកុំយកកូនរបស់លោកអ្នកធ្វើជារូបព្រះសម្រាប់អ្នកឡើយ ក្រែងព្រះទ្រង់ដកវាចេញ ហើយបំបាក់រូបព្រះរបស់លោកអ្នក ដើម្បីបញ្ចុះបញ្ចូលលោកអ្នកពីភាពល្ងង់ខ្លៅរបស់ខ្លួន!

រៀននិយាយថា «ទេ» ទៅកាន់កូនរបស់លោកអ្នក។ បង្ហាញពួកគេថា លោកអ្នកអាចបដិសេធអ្វីដែលលោកអ្នកគិតថាមិនសមនឹងពួកគេ។ បង្ហាញពួកគេថា លោកអ្នកត្រៀមខ្លួនរួចជាស្រេច ដើម្បី

ដាក់ទណ្ឌកម្មចំពោះការមិនស្តាប់បង្គាប់ ហើយថា នៅពេលលោកអ្នក
និយាយអំពីការដាក់ទណ្ឌកម្ម នោះលោកអ្នកមិនត្រឹមតែត្រៀមខ្លួន
រួចជាស្រេច ដើម្បីគំរាមកំហែងប៉ុណ្ណោះទេ ប៉ុន្តែគឺថែមទាំង ដើម្បី
អនុវត្តផងដែរ។ កុំគ្រាន់តែគំរាមកំហែង និងមិនសូវដាក់ទណ្ឌកម្ម—
ប៉ុន្តែ បើពិតជាដាក់ គឺត្រូវធ្វើដោយអស់ពីចិត្ត ប៉ុន្តែការដាក់ទណ្ឌកម្ម
ញឹកញាប់ និងតិចតួចគឺជាប្រព័ន្ធដ៏អាក្រក់។

ឪពុកម្តាយខ្លះមានទម្លាប់និយាយថា «កូនអាក្រក់» ទៅកាន់
ក្មេងប្រុស ឬក្មេងស្រីដទៃ ហើយឮនិយាយជារឿយៗដោយគ្មាន
ហេតុផលសោះ។ វាជាទម្លាប់ដ៏លូងខ្លៅណាស់។ យើងមិនគួរប្រើពាក្យ
ស្តីបន្ទោសដោយគ្មានហេតុផលពិតប្រាកដឡើយ។

ចំពោះវិធីដាក់ពិន័យកុមារដ៏ល្អបំផុត គ្មានច្បាប់ទូទៅអាចត្រូវបាន
គេដាក់ចេញទេ។ ចរិតលក្ខណៈរបស់កុមារ គឺខុសគ្នាខ្លាំងណាស់ អ្វី
ដែលជាការដាក់ពិន័យធ្ងន់ធ្ងរចំពោះកូនម្នាក់ ប្រហែលនឹងមិនធ្ងន់ធ្ងរ
ចំពោះកូនមួយទៀតនោះទេ។ ខ្ញុំគ្រាន់តែសុំចូលទៅក្នុងការតវ៉ាដែល
ជាការសម្រេចចិត្តរបស់ខ្ញុំប្រឆាំងនឹងគំនិតសម័យទំនើបដែលថា គ្មាន
កូនណាដែលមិនគួរត្រូវបានវាយប្រដៅនោះទេ។ ដោយមិនសង្ស័យ
ឪពុកម្តាយខ្លះប្រើការកែតម្រង់ខាងរាងកាយច្រើនពេក ហើយប្រើហិង្សា
ខ្លាំងពេក—ប៉ុន្តែ ខ្ញុំខ្លាចខ្លះទៀត គឺប្រើវាតិចតួចពេក។

សូមប្រយ័ត្ន ចំពោះការបណ្តោយឲ្យកំហុសតូចតាចកន្លងផុត
ទៅ ដោយមិនមាននរណាកត់សម្គាល់ក្រោមគំនិតថា «វាតូចមួយ

ប៉ុណ្ណោះ»។ មិនមានរឿងតូចតាចក្នុងការបង្ហាត់បង្រៀនកុមារទេ—ទាំងអស់សុទ្ធតែសំខាន់។ ស្មៅតូចៗត្រូវការដកច្រើនដូចស្មៅផ្សេងដែរ។ បើទុកចោលនោះមិនយូរប៉ុន្មាន វានឹងធំយ៉ាងឆាប់រហ័ស!

ឪពុកម្តាយទាំងឡាយ ប្រសិនបើមានចំណុចណាមួយដែលសមនឹងការយកចិត្តទុកដាក់របស់លោកអ្នក សូមជឿខ្ញុំ វាគឺជាចំណុចនេះ។ ជាការមួយដែលនឹងផ្តល់ឲ្យអ្នកនូវបញ្ហា ខ្ញុំដឹង។ ប៉ុន្តែប្រសិនបើលោកអ្នកមិនមានបញ្ហាជាមួយកូនរបស់លោកអ្នកនៅពេលពួកគេនៅក្មេង—ពួកគេនឹងធ្វើឲ្យលោកអ្នកមានបញ្ហានៅពេលពួកគេធំឡើង! ជ្រើសរើសមួយណាដែលលោកអ្នកចូលចិត្ត។

ជំពូក១៣

សូមបណ្តុះបណ្តាលពួកគេដោយចងចាំអំពីរបៀបដែលព្រះបណ្តុះបណ្តាលកូនៗរបស់ទ្រង់ជានិច្ច

ព្រះគម្ពីរប្រាប់យើងថា ព្រះបានរើសតាំងមនុស្ស—ជាក្រុមគ្រួសារមួយក្នុងលោកនេះ។ មនុស្សមានបាបទាំងអស់ដែលបានចាក់ចុចអំពីអំពើបាប ហើយរត់ទៅរកព្រះយេស៊ូវ ដើម្បីសេចក្តីសុខសាន្តបង្កើតបានជាក្រុមគ្រួសារនោះ។ សមាជិក គឺជាយើងទាំងអស់គ្នាដែលពិតជាជឿលើព្រះគ្រីស្ទសម្រាប់ការសង្គ្រោះ។

ឥឡូវនេះ ព្រះវរបិតាតែងតែបង្ហាត់បង្រៀនសមាជិកនៃគ្រួសារនេះ ដើម្បីនឹងរស់នៅជារៀងរហូតជាមួយទ្រង់នៅស្ថានសួគ៌។ ទ្រង់ធ្វើជាកសិករកាត់លស់ចម្ការរបស់ទ្រង់ ដើម្បីឲ្យពួកគេអាចបង្កើតផលបានកាន់តែច្រើន។ ទ្រង់ជ្រាបពីលក្ខណៈរបស់យើងម្នាក់ៗ—អំពើបាបរបស់យើងដែលកំពុងកើតឡើង—ភាពទន់ខ្សោយផ្សេងៗរបស់យើង—ជំងឺឈឺថ្កាត់ផ្សេងៗរបស់យើង។ ទ្រង់ដឹងពីកិច្ចការរបស់យើង និងកន្លែងដែលយើងរស់នៅ នរណាជាដៃគូជីវិតរបស់យើង ហើយអ្វីជាការសាកល្បងរបស់យើង អ្វីជាការល្បួងរបស់យើង និងអ្វីជាឯកសិទ្ធិរបស់យើង។ ទ្រង់ជ្រាបរឿងទាំងអស់នេះ ហើយទ្រង់តែងធ្វើទាំងអស់ ដើម្បីប្រយោជន៍របស់យើង។ ទ្រង់បានប្រទានដល់

យើងម្នាក់ៗនូវការផ្គត់ផ្គង់របស់ទ្រង់ នូវអ្វីដែលយើងត្រូវការ ដើម្បីឲ្យយើងបង្កើតផលច្រើនបំផុត—ពន្លឺថ្ងៃ និងភ្លៀងច្រើនតាមដែលយើងអាចទទួលបាន—ដូចជារបស់ជូរចត់ និងផ្អែមជាច្រើនតាមដែលយើងអាចទ្រាំបាន។ មិត្តអ្នកអាន ប្រសិនបើលោកអ្នកនឹងបង្ហាត់កូនរបស់លោកអ្នកដោយប្រាជ្ញា ចូរកត់ចំណាំនូវរបៀបដែលព្រះដ៏ជាព្រះវរបិតាបង្ហាត់បង្រៀនកូនរបស់ទ្រង់។ ព្រះអង្គធ្វើអ្វីៗគ្រប់យ៉ាងបានយ៉ាងល្អ។ ផែនការដែលទ្រង់អនុម័តត្រូវតែត្រឹមត្រូវ។

សូមមើល តើមានរបស់ប៉ុន្មានដែលព្រះបានរារាំងពីកូនៗរបស់ទ្រង់។ ខ្ញុំសន្មតថា មានតិចតួចណាស់ដែលត្រូវបានរកឃើញក្នុងចំណោមពួកគេ ។ ជារឿយៗ មានរឿងមួយដែលពួកគេចង់សម្រេច ហើយតែងតែមានឧបសគ្គខ្លះ ដើម្បីរារាំងការសម្រេចបាន។ វាហាក់ដូចជាព្រះកំពុងដាក់វានៅលើសពីការឈោងដល់របស់យើង ហើយមានបន្ទូលថា «ការនេះមិនល្អសម្រាប់លោកអ្នកទេ នេះមិនត្រូវទេ»។ លោក ម៉ូសេ ប្រាថ្នាចង់ឆ្លងទន្លេយ័រដាន់យ៉ាងខ្លាំង ដើម្បីបានឃើញទឹកដីសន្យាដ៏ល្អ។ ប៉ុន្តែ លោកអ្នកនឹងចាំថា បំណងប្រាថ្នារបស់គាត់មិនដែលបានផ្តល់ឲ្យទេ។

សូមមើលផងដែរថា តើញឹកញាប់ប៉ុណ្ណាដែលព្រះដឹកនាំរាស្ត្ររបស់ទ្រង់តាមមធ្យោបាយដែលហាក់ដូចជាពិបាក និងអាថ៌កំបាំងនៅចំពោះភ្នែករបស់យើង។ យើងមិនអាចមើលឃើញអត្ថន័យនៃការប្រព្រឹត្តទាំងអស់របស់ទ្រង់ចំពោះយើងទេ។ យើងមិនអាចមើលឃើញពី

ភាពសមហេតុផលនៃផ្លូវដែលជើងយើងដើរនោះទេ។ ពេលខ្លះ ការសាកល្បងជាច្រើនបានវាយប្រហារយើង—ការលំបាកជាច្រើន បានហុំព័ទ្ធយើង—ដែលយើងមិនអាចរកឃើញពីតម្រូវការទាំងអស់ នោះទេ។ វាហាក់ដូចជាព្រះវរបិតារបស់យើងកំពុងចាប់ដៃយើង នាំចូលទៅក្នុងទីងងឹត ហើយមានបន្ទូលថា «កុំសួរសំណួរអ្វីឡើយ ប៉ុន្តែចូរមកតាមខ្ញុំ»។ មានផ្លូវត្រង់ពីស្រុកអេស៊ីព្ទទៅស្រុកកាណាន ប៉ុន្តែអ៊ីស្រាអែលមិនបានទៅតាមនោះឡើយ ប៉ុន្តែត្រូវឆ្លងកាត់វាល រហោស្ថានវិញ។ ហើយនេះហាក់ដូចជាពិបាកនៅពេលនោះ។ យើង ត្រូវបានឃើញគម្ពីរ ប្រាប់ថា «ព្រលឹងនៃប្រជាជន» «ធ្លាក់ទឹកចិត្តជា ខ្លាំងដោយសារផ្លូវ» (និក្ខមនំ ១៣:១៧; ជនគណនា ២១:៤)។

សូមមើលផងដែរថា តើញឹកញាប់ប៉ុណ្ណាដែលព្រះប្រៀនប្រដៅ រាស្ត្ររបស់ទ្រង់ដោយការសាកល្បង និងទុក្ខព្រួយ។ ទ្រង់បានបញ្ជូន ពួកគេឆ្លងកាត់ការខកចិត្ត។ ទ្រង់បន្ទាបពួកគេដោយជំងឺ។ ទ្រង់បាន ដកហូតទ្រព្យសម្បត្តិនិងមិត្តភក្តិ។ ទ្រង់ផ្លាស់ប្តូរពួកគេពីទីតាំងមួយ ទៅទីតាំងមួយទៀត។ ទ្រង់មកជួបពួកគេជាមួយនឹងអ្វីដែលពិបាក បំផុតសម្រាប់សាច់ឈាម ហើយយើងខ្លះបានដួលសន្លប់នៅក្រោម បន្ទុកដែលដាក់មកលើយើង។ យើងមានអារម្មណ៍ថា ត្រូវបានគេ សង្កត់សង្កិនខ្លាំងហួសពីកម្លាំង ហើយស្ទើរតែត្រៀមខ្លួនជាស្រេច ដើម្បីភ្ជួញភ្ជែរពីដៃដែលប្រដៅយើង។ សាវ័ក ប៉ុល មានបន្ទាមួយ នៅក្នុងសាច់ឈាមបានតតាំងគាត់ ការសាកល្បងខាងរាងកាយដ៏

ជូរចត់ ដោយគ្មានការសង្ស័យ ទោះបីជាយើងមិនដឹងច្បាស់ថា វាជាអ្វីក៏ដោយ។ ប៉ុន្តែ យើងដឹងថា លោកបានអង្វរព្រះអម្ចាស់បីដង ដើម្បីឲ្យវាត្រូវបានដកចេញ ប៉ុន្តែទោះបីជាយ៉ាងណាវាមិនត្រូវបានយកចេញទេ (២កូរិនថូស ១២:៨,៩)។

ឥឡូវនេះ មិត្តអ្នកអាន ទោះយ៉ាងណាក៏ដោយរឿងទាំងអស់នេះ តើលោកអ្នកធ្លាប់ឮអំពីកូនណាមួយរបស់ព្រះដែលគិតថា បិតារបស់គាត់មិនបានប្រព្រឹត្តចំពោះគាត់ដោយប្រាជ្ញាទេ? ទេ ខ្ញុំប្រាកដថាលោកអ្នកមិនដែលឮទេ។ កូនរបស់ព្រះតែងតែប្រាប់លោកអ្នកថា សម្រាប់រយៈពេលវែងវាជារឿងដ៏មានពរ ដែលពួកគេមិនធ្វើតាមផ្លូវរបស់ខ្លួន ហើយថាព្រះបានធ្វើល្អជាងសម្រាប់ពួកគេ គឺល្អជាងអ្វីដែលពួកគេអាចធ្វើបានសម្រាប់ខ្លួនគេ។ មែនហើយ! ហើយពួកគេអាចប្រាប់លោកអ្នកផងដែរថា ការប្រព្រឹត្តរបស់ព្រះបានផ្តល់សុភមង្គលដល់ពួកគេច្រើនជាងអ្វីដែលពួកគេទទួលបានដោយខ្លួនឯង ហើយថាផ្លូវរបស់ទ្រង់ទោះជាងងឹតនៅពេលខ្លះ តែគឺជាផ្លូវនៃភាពរីករាយ និងជាផ្លូវនៃសេចក្តីសុខសាន្ត។

ខ្ញុំសុំឲ្យលោកអ្នកចាំនៅក្នុងដួងចិត្តនូវមេរៀនដែលការប្រព្រឹត្តរបស់ព្រះជាមួយរាស្ត្ររបស់ទ្រង់ គឺចង់បង្រៀនដល់លោកអ្នក។ សូមកុំខ្លាចយាត់កូនរបស់លោកអ្នកនូវអ្វីដែលលោកអ្នកគិតថានឹងធ្វើឲ្យពួកគេមានគ្រោះថ្នាក់ ទោះជាបំណងប្រាថ្នារបស់គាត់ជាអ្វីក៏ដោយ។ នេះគឺជាផែនការរបស់ព្រះ។

កុំស្ងាក់ស្ងើរក្នុងការដាក់បញ្ញត្តិដែលគាត់មិនអាចមើលឃើញប្រាជ្ញានាពេលបច្ចុប្បន្ននេះ ហើយត្រូវណែនាំគាត់តាមរបៀបនោះ ទោះបីឥឡូវនេះហាក់ដូចជាមិនសមហេតុផលសម្រាប់គំនិតរបស់គាត់ក្តី។ នេះគឺជាផែនការរបស់ព្រះ។ កុំបង្អង់ពីការវាយប្រដៅ និងការកែតម្រូវគាត់ រាល់ពេលដែលលោកអ្នកឃើញថា សុខភាពព្រលឹងវិញ្ញាណរបស់គាត់ត្រូវការវា—ទោះជាយ៉ាងណា វាអាចនឹងឈឺចាប់ចំពោះអារម្មណ៍របស់លោកអ្នក ហើយសូមចងចាំថា មិនត្រូវបដិសេធឱសថសម្រាប់គំនិត ពីព្រោះវាល្វីងជូរចត់ឡើយ។ នេះគឺជាផែនការរបស់ព្រះ។

ហើយកុំខ្លាចអ្វីទាំងអស់ថា ផែនការបណ្តុះបណ្តាលបែបនេះនឹងធ្វើឲ្យកូនលោកអ្នកមិនសប្បាយចិត្ត។ ខ្ញុំព្រមានលោកអ្នកអោយប្រឆាំងនឹងការភាន់ច្រឡំនេះ។ គ្មានផ្លូវទៅរកភាពមិនសប្បាយចិត្តជាងការមានផ្លូវផ្ទាល់ខ្លួនយើងឡើយ។ ដើម្បីឲ្យឆន្ទៈរបស់យើងត្រូវបានត្រួតពិនិត្យ និងធ្វើការបដិសេធ គឺជារឿងដ៏មានពរសម្រាប់យើង វាធ្វើឲ្យយើងមានតម្លៃរីករាយនៅពេលដែលវាមកដល់។ ការបណ្តោយខ្លួនជារឿងរហូត គឺជាវិធីធ្វើឲ្យមានភាពអាត្មានិយម មនុស្សអាត្មានិយម និងក្មេងខូច សូមជឿខ្ញុំ ពួកគេកម្រនឹងសប្បាយចិត្តណាស់។

មិត្តអ្នកអាន កុំព្យាយាមឆ្លាតជាងព្រះ—បង្ហាត់កូនរបស់លោកអ្នកដូចដែលទ្រង់បង្ហាត់បង្រៀនកូនរបស់ទ្រង់ចុះ។

ជំពូក១៤

សូមបណ្តុះបណ្តាលពួកគេដោយនឹកចាំអំពីឥទ្ធិពល

ការណែនាំ ដំបូន្មាន និងពាក្យបញ្ជាមានប្រយោជន៍តិចតួចណាស់ លុះត្រាតែពួកគេត្រូវបានគាំទ្រដោយគំរូជីវិតរបស់លោកអ្នកផ្ទាល់។ កូនរបស់លោកអ្នកនឹងមិនជឿថា លោកអ្នកជាមនុស្សស្មោះត្រង់ទេ ដរាបណាសកម្មភាពរបស់លោកអ្នកផ្ទុយនឹងដំបូន្មានរបស់លោកអ្នក។ លោក ធីលទ្សុតសុន (Tillotson) បានធ្វើការកត់សម្គាល់យ៉ាងឈ្លាសវៃនៅពេលគាត់លើកឡើងថា «ការផ្តល់ការណែនាំល្អដល់ក្មេងៗ ហើយផ្តល់គំរូអាក្រក់ គឺគ្រាន់តែហៅឲ្យពួកគេបែរក្បាល ដើម្បីទៅកាន់ឋានសួគ៌ ខណៈពេលដែលយើងចាប់ដៃពួកគេនាំពួកគេនៅក្នុងផ្លូវទៅឋាននរក!»

យើងដឹងតិចតួចអំពីកម្លាំង និងអំណាចនៃគំរូ។ គ្មាននរណាម្នាក់ក្នុងចំណោមពួកយើងអាចរស់នៅ ដើម្បីខ្លួនឯងនៅក្នុងពិភពលោកនេះ យើងតែងតែជះឥទ្ធិពលដល់កូនៗរបស់យើងនៅក្នុងរបៀបណាមួយ មិនថានៅក្នុងរបៀបល្អឬអាក្រក់ មិនថាសម្រាប់ព្រះឬសម្រាប់អំពើបាប។ ពួកគេឃើញមាគ៌ារបស់យើង ពួកគេសម្គាល់ការប្រព្រឹត្ត

របស់យើង ពួកគេសង្កេតមើលអាកប្បកិរិយារបស់យើង និងអ្វីដែលពួកគេឃើញយើងធ្វើ គឺដើម្បីអោយពួកគេអាចគិតថា យើងគិតត្រឹមត្រូវ។ខ្ញុំជឿថា គ្មានគំរូណាដែលត្រូវបានបង្ហាញយ៉ាងខ្លាំងក្លាដូចជាគំរូឪពុកម្តាយ និងកូននោះទេ។

ឪពុកម្តាយទាំងឡាយ សូមកុំភ្លេចថា កូនរៀនដោយភ្នែកជាងស្តាប់ដោយត្រចៀក។ គ្មានសាលាណានឹងធ្វើឲ្យមានសញ្ញាណយ៉ាងជ្រៅលើចរិតលក្ខណៈដូចជានៅផ្ទះនោះទេ។ គ្រូដែលល្អបំផុតនៅសាលានឹងមិនដក់ជាប់ក្នុងគំនិតរបស់ពួកគេច្រើន ដូចដែលពួកគេទទួលយកនៅផ្ទះរបស់លោកអ្នកឡើយ។ ការយកតម្រាប់តាមគំរូ គឺជាគោលការណ៍មានប្រសិទ្ធភាពខ្លាំងជាមួយកុមារជាងការចងចាំ។ អ្វីដែលគេមើលឃើញមានឥទ្ធិពលនៅក្នុងគំនិតគេខ្លាំងជាងអ្វីដែលគេបានឮទៅទៀត។

ដូច្នេះ ចូរប្រយ័ត្ននឹងអ្វីដែលលោកអ្នកធ្វើនៅចំពោះមុខកូន។ មានសុភាសិតដ៏ពិតមួយថា «អ្នកណាប្រព្រឹត្តបាបចំពោះមុខកូនក្មេង គឺធ្វើបាបទ្វេដង»។ ចូរព្យាយាមធ្វើជាសំបុត្រដ៏រស់របស់ព្រះគ្រីស្ទឲ្យគ្រួសាររបស់លោកអ្នកអាចអានបាន ហើយច្បាស់លាស់ដែរ។ សូមធ្វើជាគំរូនៃការគោរពព្រះបន្ទូលរបស់ព្រះ ការគោរពពេលអធិស្ឋាន ការគោរពព្រះគុណ ការគោរពថ្ងៃសម្រាករបស់ព្រះអម្ចាស់។ ធ្វើជាគំរូក្នុងពាក្យសម្តី ចិត្តល្អ ឧស្សាហ៍ព្យាយាម និរន្តរភាព ជំនឿ សប្បុរសសុភាព និងការបន្ទាបខ្លួន។ សូមកុំគិតថា កូនរបស់លោកអ្នកនឹង

អនុវត្តអ្វីដែលពួកគេមិនឃើញលោកអ្នកធ្វើឡើយ។ លោកអ្នក គឺជារូបភាពគំរូរបស់ពួកគេ—ហើយពួកគេនឹងចម្លងអ្វីដែលលោកអ្នកធ្វើ។ ការរៀកញែករបស់លោកអ្នក និងការបង្រៀនរបស់លោកអ្នក បទបញ្ជាដ៏ឈ្លាសវៃរបស់លោកអ្នក និងដំបូន្មានដ៏ល្អរបស់លោកអ្នក—ទាំងអស់នេះពួកគេប្រហែលជាមិនយល់ ប៉ុន្តែពួកគេអាចយល់ពីជីវិតរបស់លោកអ្នកបាន!

កុមារ គឺជាអ្នកសង្កេតការណ៍រហ័សណាស់—រហ័សក្នុងការមើលឃើញតាមរយៈប្រភេទលាក់ពុតមួយចំនួន—រហ័សក្នុងការស្វែងរកនូវអ្វីដែលលោកអ្នកគិត និងមានអារម្មណ៍—រហ័សក្នុងការទទួលយកគ្រប់វិធី និងគំនិតរបស់លោកអ្នក។ លោកអ្នកនឹងឃើញជាញឹកញាប់ឪពុកបែបណា—កូនក៏បែបនោះដែរ។

សូមចងចាំពាក្យដែលអធិរាជ សេសារ តែងតែប្រើចំពោះទាហានក្នុងការប្រយុទ្ធ។ គាត់មិនបាននិយាយថា «ទៅមុខ» ប៉ុន្តែ «មក!» ដូច្នេះ វាត្រូវតែដូចគ្នាជាមួយលោកអ្នកក្នុងការបណ្តុះបណ្តាលកូនរបស់ខ្លួនដែរ។ ពួកគេកម្រនឹងរៀនទម្លាប់ដែលពួកគេឃើញលោកអ្នកគ្រាន់តែនិយាយ ឬដើរក្នុងផ្លូវដែលលោកអ្នកមិនដើរដោយខ្លួនឯងឡើយ។ អ្នកណាដែលបង្ហាញដល់កូននូវអ្វីដែលខ្លួនមិនបានប្រព្រឹត្ត គឺជាការធ្វើកិច្ចការដែលមិនចេះទៅមុខ។ វាគឺដូចជារឿងប្រឌិតរបស់លោក ផេនេឡុប (Penelope) ពីបុរាណ «ដែលត្បាញពេញមួយថ្ងៃ ហើយរុះចេញពេញមួយយប់»។ ទោះជាយ៉ាងនេះក្តី ឪពុកម្តាយដែល

ព្យាយាមបង្ហាត់បង្រៀនកូនដោយមិនបានធ្វើគំរូល្អ នោះគឺជាការ
កសាងដោយដៃម្ខាង—ហើយរុះចេញវិញដោយដៃម្ខាងទៀត!

ជំពូក១៥

សូមបណ្តុះបណ្តាលពួកគេដោយចងចាំជានិច្ចនូវអំណាចនៃអំពើបាប

ខ្ញុំលើកពីចំណុចនេះយ៉ាងខ្លីគឺ ដើម្បីការពារអ្នកទាស់ប្រឆាំងជាមួយការរំពឹងទុកដែលមិនស្របតាមព្រះគម្ពីរ។

លោកអ្នកមិនត្រូវរំពឹងថា លោកអ្នកនឹងរកឃើញគំនិតរបស់កូនលោកអ្នកដូចក្រដាសសមួយសន្លឹកនោះទេ ហើយនឹងមិនមានបញ្ហាប្រសិនបើលោកអ្នកគ្រាន់តែប្រើវិធីត្រឹមត្រូវ។ ខ្ញុំព្រមានលោកអ្នកដោយច្បាស់ថា លោកអ្នកនឹងមិនរកឃើញរឿងបែបនេះទេ។ វាពិតជាឈឺចាប់ណាស់ដែលឃើញអំពើពុករលួយ និងអំពើអាក្រក់នៅក្នុងចិត្តរបស់កូនក្មេង ហើយវាចាប់ផ្តើមបង្កើតផលយ៉ាងឆាប់រហ័ស។ ចិត្តឆេវឆាវ ការមានឆន្ទៈខ្លួនឯង អំនួត ច្រណែន ភាពក្រញ៉ូវ តណ្ហាខ្ជិលច្រអូស អាត្មានិយម ការបោកបបញ្ឆោត ល្បិចកល ភាពមិនពិត ពុតត្បុត ភាពប៉ិនប្រសប់ក្នុងការរៀនអ្វីដែលអាក្រក់ ភាពយឺតយ៉ាវក្នុងការរៀនអ្វីដែលល្អ ត្រៀមខ្លួនធ្វើអ្វីៗគ្រប់យ៉ាង ដើម្បីទទួលបានទីបញ្ចប់របស់ខ្លួន—ចំណុចទាំងអស់នេះ ឬខ្លះក្នុងចំណោម

នេះ លោកអ្នកត្រូវតែត្រៀមខ្លួន ដើម្បីមើលឃើញ សូម្បីតែក្នុងសាច់ញាតិរបស់លោកអ្នក។ នៅក្នុងរបៀបតូចណាមួយ ពួកវានឹងលូតចេញទាំងនៅវ័យក្មេង វាស្ទើរតែគួរឲ្យភ្ញាក់ផ្អើលក្នុងការសង្កេតមើលពីរបៀបដែលពួកវាហាក់ដូចជារីកដុះដាលដោយធម្មជាតិ។ កុមារមិនទាមទារឲ្យរៀនសូត្រនៅសាលា ដើម្បីចេះធ្វើបាបឡើយ។

ប៉ុន្តែ លោកអ្នកមិនត្រូវបាក់ទឹកចិត្ត ហើយបោះបង់ចោលដោយព្រោះអ្វីដែលលោកអ្នកឃើញនោះឡើយ។ លោកអ្នកមិនត្រូវគិតថាវាជារឿងចម្លែក និងមិនធម្មតាទេ—ដែលថាដួងចិត្តដ៏តូចរបស់ពួកគេពោរពេញដោយអំពើបាប។ វាជាចំណែកតែមួយគត់ដែលលោក អ័ដាម ជាឪពុករបស់យើងបានបន្សល់ទុកឲ្យយើង វាគឺជាចំណែកធម្មជាតិនៃការធ្លាក់ក្នុងអំពើបាប ដែលយើងកើតមកក្នុងពិភពលោក វាជាមរតកដែលជាកម្មសិទ្ធិរបស់យើងទាំងអស់គ្នា។ សូមអនុញ្ញាតឲ្យវាធ្វើឲ្យលោកអ្នកកាន់តែឧស្សាហ៍ព្យាយាមក្នុងការប្រើប្រាស់គ្រប់មធ្យោបាយដែលហាក់ដូចជាទំនងបំផុត តាមរយៈព្រះពររបស់ព្រះ ដើម្បីទប់ទល់នឹងអំពើទុច្ចរិត។ សូមឲ្យវាធ្វើឲ្យលោកអ្នកកាន់តែមានការប្រុងប្រយ័ត្នរហូតទាល់តែលោកអ្នកជាប់នៅ ដើម្បីឲ្យកូនរបស់លោកអ្នកជៀសចេញពីផ្លូវនៃការល្បួង។

កុំស្តាប់តាមអ្នកដែលប្រាប់លោកអ្នកថា កូនអ្នកល្អ។ ផ្ទុយទៅវិញ ចូរគិតថា ចិត្តរបស់គេតែងតែឆេះដូចភ្លើង។ ក្នុងសមត្ថភាពខ្លាំងបំផុតរបស់ពួកគេ គឺពួកគាត់គ្រាន់តែត្រូវការត្រឹមតែរងើកភ្លើងដ៏តូច

មួយ ដើម្បីដុតបញ្ឆេះអំពើពុករលួយឡើង។ ឪពុកម្តាយកម្រមានការប្រុងប្រយ័ត្នណាស់។ សូមចងចាំអំពីនិស្ស័យបាបពីកំណើតរបស់កូនលោកអ្នក ហើយសូមមានការប្រុងប្រយ័ត្ន។

ជំពូក១៦

សូមបណ្តុះបណ្តាលពួកគេដោយបន្តចងចាំជានិច្ច នូវព្រះបន្ទូលសន្យា

ខ្ញុំក៏លើកចំណុចនេះយ៉ាងខ្លីដែរ ដើម្បីការពារអ្នកទាស់ប្រឆាំងនឹងការបាក់ទឹកចិត្ត។

លោកអ្នកមានសេចក្តីសន្យាយ៉ាងច្បាស់មួយ នៅខាងលោកអ្នក ថា «ចូរបង្ហាត់កូនក្មេង ឲ្យប្រព្រឹត្តតាមផ្លូវដែលគួរប្រព្រឹត្តនោះវា នឹងមិនលះបង់ពីផ្លូវនោះដរាបដល់ចាស់» (សុភាសិត ២២:៦)។ គិតពិចារណាក្នុងការមានសន្យាបែបនេះ។ ការសន្យាគឺជាចង្កៀងនៃក្តីសង្ឃឹមតែមួយគត់ ដែលលើកទឹកចិត្តដល់ដួងចិត្តរបស់បុព្វបុរស មុនពេលព្រះគម្ពីរត្រូវបានសរសេរឡើង។ លោក ហេណុក, លោក ណូអេ, លោក អ័ប្រាហាំ, លោក អ៊ីសាក, លោក យ៉ាកុប, លោក យ៉ូសែប—ពួកគាត់បានរស់នៅតាមការសន្យាមួយចំនួន ហើយបានរីកចម្រើនក្នុងព្រលឹងរបស់ពួកគាត់។ ការសន្យាគឺជាភាពស្និទ្ធស្នាលដែលនៅគ្រប់សម័យកាលបានគាំទ្រ និងចម្រើនកម្លាំងអ្នកជឿ។ អ្នកណាដែលមានព្រះបន្ទូលសន្យាយ៉ាងច្បាស់នៅខាងខ្លួនមិនត្រូវបោះបង់ចោលឡើយ។ ឪពុកម្តាយទាំងឡាយអើយ កាលណាចិត្តលោកអ្នកកំពុង

ធ្លាក់ចុះ ហើយត្រៀមខ្លួនឈប់ សូមក្រឡេកមើលពាក្យនៃព្រះបន្ទូល
សន្យានេះ ហើយទទួលយកការកម្សាន្តចិត្តចុះ។

សូមគិតអំពីអ្នកដែលសន្យា។ វាមិនមែនជាពាក្យរបស់មនុស្ស ដែល
អាចនឹងកុហក ឬផ្លាស់ប្តូរគំនិតរបស់ខ្លួនឡើយ ប៉ុន្តែ វាជាព្រះបន្ទូល
របស់ស្តេចលើអស់ទាំងស្តេចដែលមិនដែលផ្លាស់ប្តូរ។ តើទ្រង់មាន
បន្ទូលអ្វីមួយហើយទ្រង់មិនធ្វើឬទេ? ឬមួយទ្រង់មានព្រះបន្ទូល
អ្វីមួយហើយ តើទ្រង់មិនធ្វើឲ្យល្អទេឬអី? ក៏គ្មានអ្វីដែលពិបាកពេក
សម្រាប់ឲ្យទ្រង់ធ្វើដែរ។ អ្វីដែលមិនអាចទៅរួចជាមួយមនុស្សគឺអាច
ទៅរួចជាមួយព្រះ។ មិត្តអ្នកអាន ប្រសិនបើយើងមិនទទួលបានអត្ថ
ប្រយោជន៍ពីការសន្យាដែលយើងរស់នៅលើ នោះកំហុសមិនស្ថិតនៅ
ក្នុងទ្រង់ទេ ប៉ុន្តែនៅក្នុងខ្លួនយើងវិញ។

សូមគិតផងដែរនូវអ្វីដែលការសន្យាបានមាន មុនពេលដែល
លោកអ្នកបដិសេធមិនទទួលយកការកម្សាន្តចិត្តពីវា។ វានិយាយ
អំពីពេលវេលាជាក់លាក់មួយដែលការបណ្តុះបណ្តាលដ៏ល្អជា
ពិសេសនឹងបង្កើតផល—«នៅពេលកូនចាស់»។ ប្រាកដជាមានការ
កម្សាន្តចិត្តក្នុងនេះ។ លោកអ្នកប្រហែលជាមិនបានឃើញផ្លាល់
ភ្នែកនូវលទ្ធផលនៃការបណ្តុះបណ្តាលយ៉ាងប្រុងប្រយ័ត្ននោះទេ
ប៉ុន្តែលោកអ្នកមិនដឹងថាផលផ្លែណាដែលផ្តល់ពរនោះអាចនឹង
មិនកើតចេញពីវាទេ ឃ្លាទៀតបន្ទាប់ពីលោកអ្នកស្លាប់ទៅ។ វា
មិនមែនជាវិធីរបស់ព្រះក្នុងការផ្តល់អ្វីគ្រប់យ៉ាងក្នុងពេលតែមួយ

នោះទេ។ «ក្រោយមក» ជាពេលដែលទ្រង់តែងតែជ្រើសរើសធ្វើការទាំងក្នុងរឿងធម្មជាតិ និងក្នុងព្រះគុណ។ «ក្រោយមក» គឺជារដូវដែលការរងទុក្ខទទួលផលនៃសេចក្តីសុចរិតដោយសន្តិវិធី (ហេព្រើរ ១២:១១)។ «ក្រោយមក» ជាពេលដែលកូនប្រុសដែលបដិសេធមិនធ្វើការក្នុងចម្ការរបស់ឪពុកខ្លួនបានប្រែចិត្តហើយត្រលប់ទៅវិញ (ម៉ាថាយ ២១:២៩)។ ហើយ «ក្រោយមក» គឺជាពេលវេលាដែលឪពុកម្តាយត្រូវទន្ទឹងរង់ចាំ ប្រសិនបើពួកគេមិនឃើញជោគជ័យភ្លាមៗនោះទេ—លោកអ្នកត្រូវតែសាបព្រោះក្នុងក្តីសង្ឃឹម ហើយដាំដោយក្តីសង្ឃឹម។

ព្រះបន្ទូលបានចែងថា «ចូរបោះនំប៉័ងរបស់ឯងទៅលើទឹក ដ្បិតយូរថ្ងៃក្រោយមក ឯងនឹងបានសគុណនោះមកវិញ» (សាស្តា ១១:១)។ ខ្ញុំមិនសង្ស័យទេថានឹងមានកូនជាច្រើនដែលនឹងក្រោកឡើង នៅថ្ងៃជំនុំជម្រះ ហើយប្រទានពរដល់ឪពុកម្តាយរបស់ពួកគេសម្រាប់ការបណ្តុះបណ្តាលដ៏ល្អ ដែលមិនបានផ្តល់សញ្ញាណាមួយនៃការទទួលបានផលចំណេញពីវាក្នុងជីវិតរបស់ឪពុកម្តាយរបស់ពួកគេ។ ដូច្នេះ ចូរឆ្ពោះទៅមុខដោយជំនឿ ហើយត្រូវប្រាកដថា ការងាររបស់លោកអ្នកមិនត្រូវបោះចោលទាំងស្រុងឡើយ។ ហោរា អេលីយ៉ា បានលាតសន្ធឹងខ្លួនលើកូនស្ត្រីមេម៉ាយបីដងមុនពេលវារស់ឡើងវិញ។ ចូរយកគំរូពីគាត់ ហើយស៊ូទ្រាំ។

ជំពូក១៧

ចុងក្រោយ សូមបង្ហាត់ពួកគេដោយការអធិស្ឋានឥតឈប់ឈរសម្រាប់ព្រះពរលើគ្រប់អ្វីដែលលោកអ្នកធ្វើ

បើគ្មានព្រះពរពីព្រះអម្ចាស់ទេ ការខិតខំអស់ពីសមត្ថភាពរបស់លោកអ្នកនឹងគ្មានផលល្អឡើយ។ ព្រះជាម្ចាស់ស្គាល់ចិត្តរបស់មនុស្សទាំងអស់នៅក្នុងព្រះហស្តទ្រង់ ហើយលើកលែងតែទ្រង់ពាល់ចិត្តកូនរបស់លោកអ្នកដោយព្រះវិញ្ញាណទ្រង់ នោះលោកអ្នកនឹងនឿយណាយដោយគ្មានគោលបំណង។ ដូច្នេះ ចូរស្រោចទឹកគ្រាប់ពូជដែលលោកអ្នកបានសាបព្រោះក្នុងចិត្តពួកគេដោយការអធិស្ឋានឥតឈប់ឈរ។ ព្រះអម្ចាស់ទ្រង់សព្វព្រះទ័យស្តាប់ច្រើនជាងយើងអធិស្ឋានទៅទៀត ទ្រង់ត្រៀមជាស្រេច ដើម្បីផ្តល់ព្រះពរលើសជាងយើងនឹងសុំ—ប៉ុន្តែ ទ្រង់ស្រឡាញ់ការអង្វរសម្រាប់ពួកគេ។ ហើយខ្ញុំដាក់ការអធិស្ឋាននេះនៅចំពោះមុខលោកអ្នក ដូចជាកំពូលថ្ម និងគ្រានៃការទាំងអស់ដែលលោកអ្នកធ្វើ។ ខ្ញុំសន្មតថាកូនដែលអ្នកអធិស្ឋានឲ្យជាច្រើនគឺកម្រនឹងត្រូវបានបោះបង់ចោលណាស់។

មើលថែកូនចៅរបស់លោកអ្នក ដូចជាលោក យ៉ាកុប បានប្រព្រឹត្ត ដល់កូនរបស់គាត់ដែរ។ គាត់ប្រាប់លោក អេសាវ ថា ពួកគេជា «កូន ដែលព្រះទ្រង់បានប្រទានមក...ជាអ្នកបម្រើរបស់បង» (លោកុប្បត្តិ ៣៣:៥)។ មើលថែពួកគេ ដូចជា យ៉ូសែប បានធ្វើលើកូនរបស់គាត់ គាត់បានប្រាប់ឪពុករបស់គាត់ថា «នេះគឺជាកូនដែលព្រះបានប្រទាន ឲ្យខ្ញុំនៅស្រុកនេះ» (លោកុប្បត្តិ ៤៨:៩)។ ចូររាប់ពួកគេរួមជាមួយ អ្នកនិពន្ធទំនុកតម្កើងថាជា «មរតកក៏ជារង្វាន់ដែលទ្រង់ប្រទាន» (ទំនុកតម្កើង ១២៧:៣)។ រួចទូលសូមព្រះអម្ចាស់ ដោយចិត្តក្លាហាន ដ៏បរិសុទ្ធ ឲ្យទ្រង់មានព្រះហឫទ័យសប្បុរស និងមេត្តាចំពោះអំណោយ របស់ព្រះអង្គផ្ទាល់។ សូមគូសចំណាំរបៀបដែលលោក អ័ប្រាហាំ ទូល អង្វរសម្រាប់លោក អ៊ីសម៉ាអែល ដោយសារលោកស្រឡាញ់គាត់ «ឱបើសិនជាអ៊ីសម៉ាអែលនឹងរស់នៅចំពោះទ្រង់ទៅអេះ»(លោកុប្បត្តិ ១៧:១៨)។ សូមមើលពីរបៀបដែលលោកម៉ាណូអានិយាយទៅ កាន់ទេវតាអំពីលោក សាំសុន ថា «តើត្រូវឲ្យយើងខ្ញុំធ្វើតាមរបៀប យ៉ាងណា ហើយប្រព្រឹត្តចំពោះកូននោះជាយ៉ាងដូចម្តេចទៅ» (ចៅហ្វាយ ១៣:១២)។ ចូរសង្កេតមើលពីរបៀបដែលលោក យ៉ូប យកចិត្តទុកដាក់ចំពោះព្រលឹងកូនរបស់គាត់យ៉ាងណា «យ៉ូបក៏ចាត់ ទៅញែកគេចេញជាបរិសុទ្ធ រួចក្រោកឡើងពីព្រលឹមស្រាង ថ្វាយ ដង្វាយដុតតាមចំនួនកូនទាំងប៉ុន្មាន ដោយនឹកថា ក្រែងកូនអញ បានធ្វើបាប ហើយមានចិត្តលះចោលព្រះយ៉ាងណា លោកតែងតែ

ធ្វើដូច្នេះជាដរាប» (យ៉ូប ១:៥)។ ឪពុកម្តាយទាំងឡាយអើយ បើលោកអ្នកស្រឡាញ់កូនរបស់ខ្លួន ចូរទៅធ្វើដូចគ្នាដែរ។ លោកអ្នកមិនអាចដាក់ឈ្មោះពួកគេនៅមុខកៅអីនៃសេចក្តីមេត្តាញឹកញាប់ពេកទេ។

ហើយឥឡូវនេះ មិត្តអ្នកអាន ជាការសរុបសេចក្តីមក សូមមេត្តាអនុញ្ញាតឲ្យខ្ញុំសង្កត់ធ្ងន់លើលោកអ្នកម្តងទៀតពីភាពចាំបាច់ និងសារៈសំខាន់នៃការប្រើប្រាស់គ្រប់មធ្យោបាយ នៅក្នុងអំណាចរបស់លោកអ្នក ប្រសិនបើលោកអ្នកនឹងបណ្តុះបណ្តាលកូនរបស់លោកអ្នកសម្រាប់នគរស្ថានសួគ៌។

ខ្ញុំដឹងច្បាស់ថា ព្រះដ៏មានអធិបតេយ្យភាព ហើយធ្វើគ្រប់យ៉ាងស្របតាមការទូន្មាននៃព្រះហឫទ័យរបស់ទ្រង់។ ខ្ញុំដឹងថា ស្តេច រេហូបោម ជាបុត្ររបស់ស្តេច សាឡូម៉ូន ហើយស្តេច ម៉ាណាសេ ជាបុត្ររបស់ស្តេច ហេសេគា ហើយអ្នករាល់គ្នាមិនមែនតែងតែឃើញឪពុកម្តាយ ដែលគោរពកោតខ្លាចព្រះមានកូនដែលគោរពកោតខ្លាចព្រះឡើយ។ ប៉ុន្តែ ខ្ញុំក៏ដឹងដែរថា ព្រះអង្គគឺជាព្រះដែលធ្វើការដោយមធ្យោបាយ ហើយខ្ញុំប្រាកដណាស់ ប្រសិនបើលោកអ្នកមើលស្រាលនូវមធ្យោបាយដូចដែលខ្ញុំបានលើកឡើងនោះ កូនរបស់លោកអ្នកទំនងជាមិនប្រែជាល្អទេ។

ឪពុកម្តាយទាំងឡាយ លោកអ្នកអាចនាំកូនរបស់លោកអ្នកទៅក្រុមជំនុំ—លោកអ្នកអាចបញ្ជូនពួកគេទៅសាលាល្អបំផុត ហើយផ្តល់ឲ្យពួកគេនូវព្រះគម្ពីរ និងសៀវភៅអធិស្ឋាន ហើយបំពេញពួកគេ

ដោយចំណេះដឹងនៅក្នុងខួរក្បាល—ប៉ុន្តែ ប្រសិនបើគ្រប់ពេលវេលាទាំងនេះមិនមានការបណ្តុះបណ្តាលជាប្រចាំនៅផ្ទះទេ ខ្ញុំប្រាប់លោកអ្នកឲ្យដឹងច្បាស់ថា ខ្ញុំខ្លាចថាវានឹងពិបាកនៅទីបញ្ចប់ជាមួយនឹងព្រលឹងកូនៗរបស់លោកអ្នក។ ផ្ទះគឺជាកន្លែងដែលបង្កើតទម្លាប់—ផ្ទះគឺជាកន្លែងដែលចាក់គ្រឹះនៃចរិតលក្ខណៈ—ផ្ទះផ្តល់នូវទំនោរលើចំណង់ចំណូលចិត្ត ការចូលចិត្ត និងគំនិតរបស់យើង។ ហេតុនេះហើយ ខ្ញុំសូមអង្វរលោកអ្នក សូមឲ្យមានការបណ្តុះបណ្តាលនៅផ្ទះយ៉ាងយកចិត្តទុកដាក់ មានសុភមង្គល ហើយ បុរសណាដែលអាចនិយាយបានដូចដែលលោក បូលតុន (Bolton) បានធ្វើនៅពេលគាត់ដេកលើគ្រែរបស់គាត់ ហើយនិយាយទៅកាន់កូនៗរបស់គាត់ថា «ខ្ញុំមិនជឿថា គ្មាននរណាម្នាក់ក្នុងចំណោមអ្នករាល់គ្នានឹងជួបខ្ញុំនៅចំពោះមុខតុលាការរបស់ព្រះគ្រីស្ទក្នុងស្ថានភាពដែលមិនអាចបង្កើតឡើងវិញបានទេ»។

ឪពុកម្តាយទាំងឡាយអើយ ខ្ញុំសូមដាស់តឿនលោកអ្នកយ៉ាងតឹងរឹងនៅចំពោះព្រះ និងព្រះអម្ចាស់យេស៊ូវគ្រីស្ទថា ចូរខំប្រឹងគ្រប់បែបយ៉ាងដើម្បីបង្ហាត់កូនរបស់លោកអ្នកឲ្យដើរតាមផ្លូវដែលពួកគេគួរទៅ។ ខ្ញុំទូន្មានលោកអ្នកថា មិនមែនគ្រាន់តែ ដើម្បីជាប្រយោជន៍ដល់ព្រលឹងកូនរបស់លោកអ្នកឡើយ ខ្ញុំទូន្មានលោកអ្នកសម្រាប់ជាប្រយោជន៍នៃការលួងលោម និងសន្តិភាពនាពេលអនាគតរបស់លោកអ្នក។ ជាការពិត វាគឺជាចំណាប់អារម្មណ៍របស់លោកអ្នកក្នុង

ការធ្វើវា។ សុភមង្គលផ្ទាល់ខ្លួនរបស់លោកអ្នកពិតជាអាស្រ័យលើវា។ ក្មេងៗធ្លាប់ជាផ្លែដែលព្រួញមុតបំផុតចាក់ចំបេះដូងមនុស្ស! ក្មេងៗបានលាយពែងដ៏ជូរចត់បំផុតដែលមនុស្សមិនធ្លាប់ផឹក! ក្មេងៗបានធ្វើឲ្យមនុស្សប្រុសស្រក់ទឹកភ្នែកយ៉ាងក្រៀមក្រំបំផុត! លោក អ័ដាម អាចប្រាប់លោកអ្នកដូច្នេះ លោក យ៉ាកុប អាចប្រាប់លោកអ្នកដូច្នេះ ស្តេច ដាវីឌ ក៏អាចប្រាប់លោកអ្នកដូច្នេះដែរ។ លើលោកនេះគ្មានទុក្ខសោកណាដូចការដែលកូនបាននាំមកលើឪពុកម្តាយទេ! អូ! ចូរប្រយ័ត្នក្រែងការធ្វេសប្រហែសរបស់ខ្លួនឯងនឹងនាំទុក្ខដល់លោកអ្នកក្នុងវ័យចាស់។ ចូរប្រយ័ត្ន ក្រែងលោកអ្នកយំក្រោមការប្រព្រឹត្តរបស់កូនដែលគ្មានគុណធម៌ ក្នុងថ្ងៃដែលភ្នែកលោកអ្នកងងឹត ហើយកម្លាំងរបស់លោកអ្នកបានចុះខ្សោយ។

ប្រសិនបើលោកអ្នកប្រាថ្នាឲ្យកូនរបស់លោកអ្នកជាអ្នកស្តារឡើងវិញនូវជីវិតរបស់លោកអ្នក និងជាអ្នកមើលថែរក្សាលោកអ្នកនៅពេលអ្នកមានវ័យចាស់—ប្រសិនបើលោកអ្នកនឹងឲ្យពួកគេទទួលព្រះពរ ហើយមិនមែនបណ្តាសា—សេចក្តីអំណរ មិនមែនទុក្ខព្រួយ—យូដា និងមិនមែន រូបេន—នាង រស់ និងមិនមែន អ័រប៉ា—ប្រសិនបើលោកអ្នកមិនចង់ ដូចលោក ណូអេ ដែលត្រូវខ្មាសដោយទង្វើរបស់កូនៗ ហើយដូចជានាង រេបិកា ត្រូវនឿយហត់ក្នុងជីវិតដោយសារពួកគេ—ប្រសិនបើនេះជាបំណងប្រាថ្នារបស់លោកអ្នក ចូរចងចាំដំបូន្មានរបស់ខ្ញុំជានិច្ច បង្ហាត់ពួកគេក្នុងកាលនៅក្មេងតាមរបៀប

ត្រឹមត្រូវ។

ហើយសម្រាប់ខ្ញុំ ខ្ញុំនឹងបញ្ចប់ដោយសេចក្តីអធិស្ឋានរបស់ខ្ញុំទៅកាន់ព្រះសម្រាប់អស់អ្នកដែលអានអត្ថបទនេះ ដើម្បីឲ្យអ្នកទាំងអស់គ្នាទទួលការបង្រៀនពីព្រះឲ្យមានអារម្មណ៍យល់ពីតម្លៃនៃព្រលឹងរបស់លោកអ្នក។ នេះជាមូលហេតុមួយដែលការជ្រមុជទឹកច្រើនតែជាទម្រង់តែមួយ ហើយការបង្ហាត់បង្រៀនរបស់គ្រីស្ទានត្រូវបានគេមើលងាយ និងមិនយកចិត្តទុកដាក់។ ជាញឹកញាប់ឪពុកម្តាយមានអារម្មណ៍ថា មិនសម្រាប់ខ្លួនពួកគេ ហេតុដូច្នេះពួកគេមានអារម្មណ៍ថា មិនមែនសម្រាប់កូនរបស់ពួកគេដែរ។ ពួកគេមិនដឹងពីភាពខុសគ្នាយ៉ាងខ្លាំងរវាងស្ថានភាពនៃធម្មជាតិ និងស្ថានភាពនៃព្រះគុណទេ ដូច្នេះហើយពួកគេពេញចិត្តក្នុងការទុកវាឲ្យនៅម្នាក់ឯង។

ឥឡូវនេះ សូមព្រះអម្ចាស់បង្រៀនអ្នករាល់គ្នានូវអំពើបាបទាំងប៉ុន្មានជាអំពើគួរស្អប់ខ្ពើម ដែលព្រះអម្ចាស់ស្អប់។ ខ្ញុំដឹងថា បន្ទាប់មកលោកអ្នកនឹងកាន់ទុក្ខចំពោះអំពើបាបរបស់កូនលោកអ្នក ហើយព្យាយាមដកវាចេញដូចជាគ្រាចេញពីភ្លើង។

សូមព្រះអម្ចាស់បង្រៀនអ្នកទាំងអស់គ្នាអំពីតម្លៃរបស់ព្រះគ្រីស្ទ និងកិច្ចការដ៏អស្ចារ្យ ហើយពេញលេញដែលទ្រង់បានធ្វើសម្រាប់សេចក្តីសង្គ្រោះរបស់យើង។ បន្ទាប់មក ខ្ញុំមានអារម្មណ៍ជឿជាក់ថា លោកអ្នកនឹងប្រើគ្រប់មធ្យោបាយ ដើម្បីនាំកូនទៅរកព្រះយេស៊ូវ ដើម្បីឲ្យពួកគេអាចរស់នៅតាមរយៈទ្រង់។

សូមព្រះអម្ចាស់បង្រៀនលោកអ្នកនូវរាល់តម្រូវការរបស់លោកអ្នក អំពីព្រះវិញ្ញាណបរិសុទ្ធ ដើម្បីកែជាថ្មី ញែកជាបរិសុទ្ធ និងធ្វើឲ្យព្រលឹងលោកអ្នកមានជីវិតរស់ឡើងវិញ។ បន្ទាប់មក ខ្ញុំមានអារម្មណ៍ថា លោកអ្នកនឹងជំរុញកូនរបស់លោកអ្នកឲ្យអធិស្ឋានរកទ្រង់ដោយឥតឈប់ឈរ ហើយមិនសម្រាកឡើយរហូតដល់ទ្រង់យាងចុះមកក្នុងដួងចិត្តរបស់ពួកគេដោយអំណាច ហើយបង្កើតពួកគេជាមនុស្សថ្មី។

ប្រសិនបើព្រះអម្ចាស់សព្វព្រះហឫទ័យនឹងការនេះ នោះខ្ញុំសង្ឃឹមយ៉ាងមុតមាំថា លោកអ្នកពិតជានឹងបង្ហាត់បង្រៀនកូនរបស់លោកអ្នកឲ្យបានល្អ—បណ្តុះបណ្តាលឲ្យបានល្អសម្រាប់ជីវិតនេះ និងសម្រាប់ជីវិតនៅខាងមុខ—បណ្តុះបណ្តាលឲ្យបានល្អសម្រាប់ពេលនៅផែនដី ហើយសម្រាប់ពេលទៅស្ថានសួគ៌—បណ្តុះបណ្តាលពួកគេសម្រាប់ព្រះអម្ចាស់ សម្រាប់ព្រះគ្រីស្ទ និងសម្រាប់ភាពអស់កល្បជានិច្ច!

អានបន្ថែមនៅ៖



ហើយទាញយកសៀវភៅជាច្រើនទៀតដោយឥតគិតថ្លៃ

CambodianChristianResources.com

ចូលរួមក្រុម

Telegram

ដើម្បីទទួលមេរៀនព្រះបន្ទូល
រៀងរាល់ថ្ងៃ

t.me/khmerdailymanna

